គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា

THE BAR ASSOCIATION OF KINGDOM OF CAMBODIA

មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី

LAWYER TRAINING CENTER

មុខវិជ្ជា

នីតិរដ្ឋបាលទូទៅ

បង្រៀនដោយ ៖

សាស្ត្រាចារ្យ ស៊ូ សុជាតិ

មុខវិជ្ជានេះ រៀបរៀងឡើងសម្រាប់បង្រៀនសិស្សមេធាវី ជំនាន់ទី១៣

ឆ្នាំ២០១៤

~រក្សាសិទ្ធិ~

អត្ថបទទី១ : ប្រភព និងន័យមន័យនៃនីតិរដ្ឋបាល

--------**********-------

អំពីរដ្ឋបាលសាធារណៈ

ពាក្យថា *រដ្ឋបាល* អាចសំដៅទៅលើ សកម្មភាពគ្រប់គ្រង ឬ ទៅលើអង្គការគ្រប់គ្រង ។ ជាធម្មតា រដ្ឋបាលសាធារណៈ តែងត្រូវបានប្រើជាមួយ រដ្ឋ ឬ សមូហភាពសាធារណៈ ដែលមានគោលដៅបំរើប្រយោជន៍សាធារណៈ មិនគិតពីប្រយោជន៍ផ្ទាល់ខ្លួន ។ ក្រោមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣ យើងមានស្ថាប័ននយោបាយចំនួន ០៣ គឺ ស្ថាប័ននីតិបញ្ញត្តិ ស្ថាប័ននីតិប្រតិបត្តិ និង ស្ថាប័នតុលាការ ។ រដ្ឋបាលសាធារណៈត្រូវបានកំណត់ថា ជាក្រុមនៃបុគ្គលដែលបំរើការងារគាំទ្រឱ្យអំណាចនយោបាយទាំងនេះ ។ ដូចនេះ រដ្ឋបាលសាធារណៈ ត្រូវបានរៀបចំជារចនាសម្ព័ន្ធដោយឡែកៗ ទៅតាមតម្រូវការនៃអំណាចនយោបាយនីមួយៗ ។

រដ្ឋបាលសាធារណៈ មានគោលដៅខុសពីឯកជន ត្រង់ការគិតពីប្រយោជន៍ទូទៅ របស់សង្គមជាតិទាំងមូល ដែលគេហៅថា *ផលប្រយោជន៍សាធារណៈ* ។ ពួកឯកជន គេគិតពីផលប្រយោជន៍របស់ខ្លួនគេជាមុនសិន ដូច ជាការខិតខំរកស៊ីឱ្យបានចំណេញ មានលុយកាក់ច្រើនផ្ទាល់ខ្លួន មានមុខមានមាត់ក្នុងសង្គម ឬជួនកាល ខំបំរើតែឧត្តមគតិរបស់ខ្លួនម្នាក់ឯងផ្ទាល់ ។

ផលប្រយោជន៍ទូទៅ គឺជាការធ្វើឱ្យសំរេចនូវអ្វីៗ ដែលជាការចាំបាច់របស់មនុស្សរស់នៅរួមគ្នា ហើយផលសំរេចនេះ តែងទាក់ទងដល់ផលប្រយោជន៍នៃជនម្នាក់ៗ ។ ការកសាង ដូចជា ការធ្វើផ្លូវថ្នល់ ស្ពាន ជាការធ្វើឡើងសម្រាប់ផលប្រយោជន៍ទូទៅ សម្រាប់ជនទាំងអស់ដែលរស់នៅ ឬមកស្នាក់អាស្រ័យក្នុងប្រទេស ។ រដ្ឋបាលសាធារណៈ តែងខិតខំស្វែងរកនូវការបំរើផលប្រយោជន៍ទូទៅឱ្យបានសំរេច មុនអ្វីៗទាំងអស់ ។ ការអនុវត្តសមត្ថកិច្ចនេះ ក៏ត្រូវមានការប្រុងប្រយ័ត្ន ដើម្បីការគ្រប់គ្រងឱ្យបានល្អត្រឹមត្រូវ មិនខ្ជះខ្ជាយ មិនបំផ្លាញទ្រព្យសម្បត្តិសាធារណៈ មានទ្រព្យសម្បត្តិរដ្ឋជាដើម។ បច្ចុប្បន្ននេះ ប្រទេសលោកខាងលិច គេកំពុងធ្វើការវិវត្តទៅរកបច្ចេកទេសទំនើបនៃការគ្រប់គ្រង តាមបែបឯកជន ក្នុងការគ្រប់គ្រងសកម្មភាពមានលក្ខណៈបែប

សេដ្ឋកិច្ចរបស់ស្ថាប័នរដ្ឋបាលសាធារណៈ ដើម្បីកាត់បន្ថយនូវចំណាយមិនមានប្រយោជន៍ ដែលហៅថា *បរច្ចកទេសនៃការគ្រប់គ្រងទំនើប* ។

ការបំរើផលប្រយោជន៍ទូទៅ ទាមទារឱ្យរដ្ឋបាលសាធារណៈមាននូវមធ្យោបាយសមស្រប ដែលតែងតែមានឧត្តមភាពលើផលប្រយោជន៍ឯកជន ។ *ឧត្តមភាព ឬ ភាពជាធំ* គឺសំដៅទៅលើសិទ្ធិអំណាចមិនមែនបញ្ហាទំហំរូបរាងសម្ភារៈ ឬចំនួន បរិមាណនោះទេ ។ សិទ្ធិអំណាចធំនេះ ត្រូវបានកំណត់ក្រោមពាក្យថា *បុព្វសិទ្ធិនៃអំណាចសាធារណៈ* ។ បុព្វសិទ្ធិនេះ អនុញ្ញាតឱ្យរដ្ឋបាលសាធារណៈ មានប្រៀបជាងឯកជនជានិច្ច ក្នុងទំនាក់ទំនងសង្គម ។ ដោយសារមានបុព្វសិទ្ធិនៃអំណាចសាធារណៈ រដ្ឋបាលសាធារណៈមានអំណាចប្រើកំលាំងសាធារណៈ ដូចជាកំលាំងនគរបាល និងទាហាន ជាដើម។ បុព្វិសិទ្ធិនេះ ជាមធ្យោបាយសំខាន់របស់រដ្ឋបាលសាធារណៈ សម្រាប់បំរើគោលដៅធំរបស់ខ្លួន គឺផលប្រយោជន៍សាធារណៈ ។ ប៉ុន្តែ រដ្ឋបាលសាធារណៈ មិនអាចនឹងធ្វើអ្វីតាមទំនើងចិត្ត ក្រៅអំពីក្របខណ្ឌច្បាប់បានឡើយ ។

ការដាក់ឱ្យរដ្ឋបាលសាធារណៈស្ថិតក្រោមច្បាប់

គ្រប់រដ្ឋអធិប្បតេយ្យ ជាពិសេស រដ្ឋដែលប្រកាន់យកលិទ្ធិប្រជាធិបតេយ្យ តែងខិតខំគោរពតាមសញ្ញាណ " នីតិរដ្ឋ " ។ ក្នុងន័យនេះ " នីតិរដ្ឋ " សំដៅដល់ រដ្ឋដែលទាំងអ្នកកាន់អំណាចរដ្ឋ ទាំងរាស្ត្រចាត់ទុក " ច្បាប់ " ជាទីសក្ការៈដែលត្រូវគោរព និងអនុវត្តតាមយ៉ាងខ្ជាប់ខ្ជួន និងត្រឹមត្រូវ ។ រដ្ឋ និង រាស្ត្រត្រូវស្ថិតនៅក្រោមច្បាប់ទាំងអស់ ហើយគេមានជំនឿទុកចិត្តទាំងស្រុងលើច្បាប់ ដែលគេចាត់ទុកថាមានឧត្តម-គតិយុត្តិធម៌ជានិច្ច ។ គេយល់ថា ច្បាប់ជាឆន្ទៈរបស់ប្រជាជាតិ ដែលគ្មានអ្វីអាចនៅពីលើបាននោះទេ ។

រដ្ឋដែលមានច្បាប់គ្រប់គ្រងល្អ គឺរដ្ឋដែលឈរលើគោលការណ៍សកលនៃឧត្តមគតិយុត្តិធម៌ ឈរលើតម្លៃសកលនៃលទ្ធិប្រជាធិបតេយ្យសេរី និងសិទ្ធិមនុស្ស ។ ហើយចំពោះច្បាប់ទាំងនោះ គេត្រូវគោរពអនុវត្តតាមឱ្យបានល្អត្រឹមត្រូវ ក្នុងប្រព័ន្ធមួយដែលមានការត្រួតពិនិត្យ និងការទទួលខុសត្រូវ និងមានយុត្តិធម៌យ៉ាងជាក់លាក់ ។ សឹងតែគ្រប់ប្រទេសនៃលោកសេរី គេមានអង្គការកំពូលមួយសម្រាប់ត្រួត ពិនិត្យធម្មនុញ្ញភាពនៃច្បាប់ ដើម្បីពង្រឹងនីតិរដ្ឋ ។ បារាំង និងកម្ពុជា ឱ្យឈ្មោះអង្គការនេះថា *ក្រុមប្រឹក្សាធម្មនុញ្ញ* ។ នៅប្រទេសផ្សេងទៀត គេហៅថា *តុលាការធម្មនុញ្ញ* ដោយផ្អែកតាមអំណាចតូច ឬ ធំ ដែលច្បាប់បានប្រគល់ឱ្យអង្គការកំពូលនេះ ។ នៅក្នុងប្រទេសប្រកាន់យកប្រព័ន្ធច្បាប់ខូម៉ុនឡ " Common Law" តុលាការកំពូលនេះ មានសមត្ថកិច្ចជាអ្នកត្រួតពិនិត្យធម្មនុញ្ញភាពផងដែរ ។

ដូច្នេះ គ្រប់រដ្ឋទំនើបនាពេលបច្ចុប្បន្ន ដែលព្យាយាមគោរពតាមលំអាននៃគោលការណ៍ " នីតិរដ្ឋ " ត្រូវមានច្បាប់ចាប់បង្ខំឱ្យរាស្ត្រ ជាពិសេស អ្នកកាន់អំណាចរដ្ឋ ពោលគឺ រដ្ឋបាលសាធារណៈ ត្រូវគោរពតាម

និងអនុវត្ត ដោយមាននូវយន្តការត្រួតពិនិត្យការអនុវត្ត និង ដាក់ទណ្ឌកម្មលើករណីរំលោភបំពានច្បាប់ ។ រដ្ឋបាលសាធារណៈ ត្រូវស្ថិតនៅក្រោមច្បាប់ ។

ប្រភពនៃនីតិរដ្ឋបាល

ទី១- អ្នកច្បាប់ទាំងឡាយទទួលស្គាល់យក " ប្រភពសរសេរ " ទុកជាប្រភពត្រឹមត្រូវនៃនីតិរដ្ឋបាល ដែលរួមមាន : រដ្ឋធម្មនុញ្ញ សន្ធិសញ្ញាអន្តរជាតិ ច្បាប់ដែលអនុម័តដោយសភាជាតិ និងបទបញ្ជាដែលចេញពីរាជរដ្ឋាភិបាល ។ ច្បាប់ទាំងអស់នេះ គេហៅថា " ប្រភពធម្មនិយាម " គឺមានន័យថា ជាប្រភពនៃវិធានទូទៅដែលមានអានុភាពអនុវត្តជាគោលការណ៍ ជាគ្រឹះគតិយុត្ត លើរាល់សកម្មភាពនៃបុគ្គលសាធារណៈ ក្នុងកិច្ចការរដ្ឋបាល ។ ការប្រព្រឹត្តបំពានលើប្រភពធម្មនិយាមនេះ ជាការប្រព្រឹត្តខុសច្បាប់ ។

-***រដ្ឋធម្មនុញ្ញ*** : មាត្រា ១៥០ ថ្មី កថាខណ្ឌទី១ នៃរដ្ឋធម្មនុញ្ញរបស់កម្ពុជា ចែងកំណត់ថា "រដ្ឋធម្មនុញ្ញនេះ ជាច្បាប់កំពូល នៃព្រះរាជាណាចក្រកម្ពុជា"។ រដ្ឋធម្មនុញ្ញកម្ពុជា គឺរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ ដែលត្រូវបានធ្វើវិសោធនកម្មជាច្រើនលើក ដែលចុងក្រោយនៅឆ្នាំ ២០០៨ ។

-***សន្ធិសញ្ញាអន្តរជាតិ*** : នៅក្នុងប្រព័ន្ធច្បាប់របស់កម្ពុជា គឺពុំទាន់មានបញ្ញត្តិណាមួយ ដែលចែងកំណត់ថា សន្ធិសញ្ញាអន្តរជាតិស្ថិតនៅលំដាប់ថ្នាក់ទាបជាងរដ្ឋធម្មនុញ្ញ និងនៅលើច្បាប់ជាតិនោះឡើយ ។ ជាគោលការណ៍ សន្ធិសញ្ញាអន្តរជាតិត្រូវផ្តល់សច្ចាប័ន ដោយច្បាប់ជាតិ ។ នៅក្នុងទំនាក់ទំនងរវាង ប្រព័ន្ធច្បាប់ជាតិ និងប្រព័ន្ធច្បាប់អន្តរជាតិនេះ យើងគួរអនុវត្តតាមទ្រឹស្តី "ឯកនិយម - *Monisme*" និង "ទ្វិកនិយម - *Dualisme*" ។

-***ច្បាប់*** : តាមរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ ច្បាប់បែងចែកជា *ច្បាប់រៀបចំអង្គការ និងច្បាប់ធម្មតា* ដែលអនុម័តចេញដោយអំណាចនីតិបញ្ញត្តិ និងប្រកាសឱ្យប្រើដោយព្រះរាជក្រមរបស់ព្រះមហាក្សត្រជាព្រះប្រមុខរដ្ឋ ។

-***បទបញ្ជា*** : អំណាចនីតិប្រតិបត្តិ ដាក់ចេញនូវបទបញ្ជា ក្រោមរូបភាពជា *ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និង ជីកា* ។ តាមការអនុវត្តជាក់ស្តែង វិធានច្បាប់អនុម័តដោយនីតិប្រតិបត្តិ ក៏អាចត្រូវបានដាក់ចេញតាមរយៈ *សេចក្តីសម្រេចនានា ជាបទបញ្ជារាជរដ្ឋាភិបាល* ឬរបស់អាជ្ញាធរមានសមត្ថកិច្ចផ្សេងៗផងដែរ ។

ទី២- "*ប្រភពបរវេណី ឬ ទំនៀមទំលាប់*" "*ប្រភពយុត្តិសាស្ត្រ*" និង "*ប្រភពគោលការណ៍ទូទៅនៃនីតិ*" ជា "ប្រភពឥតសរសេរ " នៃនីតិ ។ លទ្ធិ ឬ ទ្រឹស្តីរបស់អ្នកប្រាជ្ញខាងច្បាប់ គ្រាន់តែជាប្រភពប្រយោលប៉ុណ្ណោះ ។

-**បវេណី ឬ ទំនៀមទំលាប់** : "ទំលាប់ " នឹងក្លាយជា "បវេណី " លុះត្រាតែយុត្តិសាស្ត្រ ធ្លាប់បានទទួលស្គាល់ និងឱ្យតម្លៃទុកដូចជាច្បាប់ ។ "ទំលាប់ " ដែលមន្ត្រីរាជការប្រតិបត្តិតាមតៗគ្នាមក គ្រាន់តែជារបៀបធ្វើការមួយ ដែលគ្មានអ្នកណាដឹងឱ្យច្បាស់ថា ជារបៀបធ្វើត្រឹមត្រូវ ឬខុសនោះទេ ។ លុះពេលមានរឿងក្តីកើតឡើង ចៅក្រមជាអ្នកតាំងសំរេចថា របៀបធ្វើការនេះ ត្រូវ ឬ ខុស ។ ចាប់ពីពេលនោះមក ទើបគេអាចនិយាយបានថា "ទំលាប់" នោះទៅជា "បវេណី" ក្នុងប្រព័ន្ធច្បាប់បាន ។

-**យុត្តិសាស្ត្រ** : "*អំណាចឆន្ទនិយាម*" ជាអំណាចបង្កើតវិធានច្បាប់ ពោលគឺវិធានដែលមានលក្ខណៈបង្ខំឱ្យបុគ្គលត្រូវតែគោរពតាម ហើយនិងដែលមានអំណាចដាក់ទណ្ឌកម្មផង ។ សេចក្តីសម្រេចយុត្តាធិការទាំងឡាយណាដែលមានអំណាចឆន្ទនិយាមនេះ គឺត្រូវបានអ្នកច្បាប់ហៅថា "យុត្តិសាស្ត្រ" ។ ជាគោលការណ៍ច្បាប់មុខងារចៅក្រម គឺកាត់ក្តី ក្នុងរឿងវិវាទបុគ្គល ។ ជាពិសេស ចំពោះចៅក្រមរដ្ឋបាល គឺការកាត់ក្តីក្នុងរឿងវិវាទរវាងភាគីឯកជន និងភាគីរដ្ឋបាលសាធារណៈ ។ ចៅក្រមជំរះក្តីតាមអ្វីដែលគេប្តឹងមក ដើម្បីរកខុសរកត្រូវ តាមគតិយុត្តិធម៌ និងតាមច្បាប់ជាធរមាន ។ ដូចនេះ ចៅក្រមមិនគួរមានសិទ្ធិ ឬ អំណាចបង្កើតវិធានច្បាប់ដែលជាវិធានទូទៅសម្រាប់អនុវត្តទៅលើគ្រប់ករណីក្រោយៗទៀតនោះទេ ។ ប៉ុន្តែ ករណីច្បាប់ចែងមិនច្បាស់លាស់ ឬ មានកន្លែងងងឹត ឬ មិនមានចែង ចៅក្រមមិនអាចដកថយនោះទេ គឺត្រូវស្វះស្វែងដោះស្រាយឱ្យទាល់តែបាន ដែលរហូតកំណត់ចេញជាវិធានច្បាប់ដែលខ្វះខាតសម្រាប់ករណីបណ្តឹងមកនេះ ។ បើយើងពិនិត្យមើលការអនុវត្តច្បាប់ដូចករណីប្រទេសបារាំង វិធានដែលចៅក្រមរដ្ឋបាល និងសាលាជំរះសមត្ថកិច្ច បានរកឃើញសម្រាប់ដោះស្រាយរឿងក្តីរដ្ឋបាល ចៅក្រមទាំងនោះច្រើនតែប្រកាន់ខ្ជាប់ជានិច្ច ក្នុងការកាត់ក្តី សម្រាប់ករណីក្រោយៗ ដែលមានអង្គហេតុដូចគ្នា ។ បើចៅក្រមនោះកាត់ក្តីរឿងដូចគ្នា ម្តងអញ្ចេះ ម្តងអញ្ចេះ ចៅក្រមនោះយល់ថា វិធានដែលខ្លួនបានខំរកឃើញថាល្អ នឹងត្រូវអស់តម្លៃ ហើយក៏អស់តម្លៃខ្លួនឯងដែរ ដែលជាហេតុនាំឱ្យគេលែងគោរពចៅក្រម ។ ម្យ៉ាងទៀត ចៅក្រមខំការពារអ្វីដែលគេហៅថា *"ស្ថិរភាពគតិយុត្ត* " ដែលសំដៅដល់ភាពជាប់បេះនៃវិធានច្បាប់ ។ ចៅក្រមនឹងដូរវិធានរបស់ខ្លួន លុះត្រាតែមានការវិវត្តសង្គមដល់កំរិតដែលគួររកវិធានថ្មី ដោយសមហេតុសមផល ប៉ុន្តែ លទ្ធភាពនេះមិនមានអ្វីដែលធ្វើឱ្យបាត់លក្ខណៈបង្ខំ របស់វិធានដែលត្រូវដូរនោះឡើយ ។ លក្ខណៈទាំងពីរនេះ គឺ *បង្ខំ និង ទណ្ឌកម្ម* នៃវិធានចៅក្រម ដែលគេហៅថា "*វិធានយុត្តិសាស្ត្រ*" នោះ ដែលពិតជាលក្ខណៈនៃវិធានច្បាប់ ។ ហេតុដូចនេះហើយបានជាគេចាត់ទុកយុត្តិសាស្ត្រ ជាប្រភពនៃនីតិពេញលក្ខណៈ ។ ចៅក្រមមិនជាប់ចំណងនឹង វិធានរបស់ខ្លួននោះទេ ប៉ុន្តែរាស្ត្រ និងរដ្ឋបាលសាធារណៈ ត្រូវជាប់ចំណងនេះ ដោយត្រូវគោរពតាមសេចក្តីសម្រេចជាស្ថាពររបស់ចៅក្រម បើមិនដូច្នោះទេ នឹងត្រូវទទួលទណ្ឌកម្ម ដូចការមិនគោរពវិធាននៃច្បាប់សរសេរ នោះដែរ ។ *នៅប្រទេសបារាំង គេរមែងយកសេចក្តីសម្រេចរបស់តុលាការកំពូល ទុកជាយុត្តិសាស្ត្រ ។*

-គោលការណ៍ទូទៅនៃនីតិ : តាមការសិក្សាបែបទស្សនៈវិជ្ជា យើងអាចដឹងបានថា មានច្បាប់ធម្មជាតិ ដែលភាសាឡាតាំងហៅថា *Jus naturale* ដែលស្ថិតនៅក្នុងវិចារណញ្ញាណរបស់មនុស្សលោក ។ ច្បាប់ធម្មជាតិ គឺកើតមានមុនច្បាប់ជាក់ស្តែង (droit positif) ហើយបើយើងប្រៀបធៀបទៅនឹងប្រវត្តិសាស្ត្រ គឺជា "បុរេនីតិ - *Pré-droit* "។ ក្នុងសម័យដើមដែលមិនទាន់មានច្បាប់ជាក់ស្តែងនោះ ទស្សនៈវិទូទាំងឡាយ គ្រាន់តែជាអ្នកគិត ប៉ុន្តែពុំមានអំណាចធ្វើអ្វីមួយឱ្យទៅជាច្បាប់ ដែលជាវិធានបង្ខំឱ្យគេគោរព និងដែលអាចដាក់ទណ្ឌកម្ម ចំពោះអ្នកដែលមិនគោរពតាម ។ ដោយឡែក ចៅក្រមទទួលបាននូវអំណាចទាំងនេះ ក្នុងនាមជាអ្នកកាត់ក្តី ជាអាជ្ញាកណ្តាល ឈរលើគោលការណ៍អព្យាក្រឹត្យ ឧត្តមគតិយុត្តិធម៌ និងកាន់សច្ចធម៌ក្នុងខ្លួន ។ ជាក់ស្តែង ប្រព័ន្ធច្បាប់ខូម៉ន ឡ Common Law គឺមានមូលដ្ឋានចេញមកពីប្រវត្តិដើមនៃអំណាចរបស់ចៅក្រមនេះឯង ។ ប្រព័ន្ធច្បាប់រ៉ូមាំង-អាឡឺម៉ង់ដ៏ ក៏មិនអាចបំភ្លេចចោលនូវអំណាចដើមរបស់ចៅក្រមនេះដែរ ថ្វីបើគេមានមូលដ្ឋានធំចេញពីនីតិការ ឬ ការធ្វើច្បាប់សរសេរក៏ដោយ ។ នៅខណៈដែលអត្ថបទច្បាប់ពុំមានចែង ឬ ចែងមិនច្បាស់លាស់ ចៅក្រមត្រឡប់ទៅរកអំណាចដើមរបស់ខ្លួនវិញ ដោយធ្វើការបកស្រាយច្បាប់ ស្វែងរកគោលការណ៍ដែលមានស្រាប់ក្នុង "យុត្តិធម៌ធម្មជាតិ " (natural justice) ដែលជាច្បាប់ធម្មជាតិ (*Jus naturale*) នោះ ។ គោលការណ៍នេះ ជាគោលការណ៍តតសរសេរ ដែលចៅក្រមមិនបានបង្កើតមក គឺចៅក្រមរកឃើញ ដែលហៅថា *"គោលការណ៍ទូទៅនៃនីតិ"*។ ជាបទពិសោធន៍របស់ច្បាប់បារាំង គោលការណ៍ដែលចៅក្រមរដ្ឋបាលលើក យកមកនោះ មិនមែនជាមតិផ្ទាល់ខ្លួនរបស់ចៅក្រមដែលចេះតែយល់ឃើញ តាមចិត្តនឹកឃើញនោះទេ ។ គោលការណ៍នោះ ថ្វីបើមិនសរសេរទុក តែត្រូវមានអត្ថិភាពពិតប្រាកដ ក្នុងស្ថានភាពណាមួយរបស់ប្រទេស ហើយដែលស្របទៅនឹងការយល់ព្រមជាទូទៅរបស់មហាជនផងដែរ ។ លក្ខណៈនេះបង្ហាញថា គោលការណ៍ទូទៅនៃនីតិអាចមានការវិវត្តប្រែប្រួល ទៅតាមសភាពការណ៍របស់ប្រទេស ក៏ដូចជាការប្រែប្រួលរបស់ច្បាប់ដែរ ។

និយមន័យនីតិរដ្ឋបាល

នៅក្នុងប្រព័ន្ធច្បាប់បារាំង វិធានគតិយុត្ត ដែលគ្រប់គ្រងសកម្មភាពរដ្ឋបាលសាធារណៈ មិនដូចវិធានគតិយុត្តនៃនីតិឯកជននោះទេ ពីព្រោះរដ្ឋដែលជានីតិបុគ្គលសាធារណៈ មាននូវបុព្វសិទ្ធិនៃអំណាចសាធារណៈ ដែលនាំឱ្យរដ្ឋការមានឧត្តមភាពជានិច្ចលើវាស្ត្រ ។ ទោះបីរដ្ឋបាលសាធារណៈ ត្រូវស្ថិតនៅក្រោមច្បាប់ ទាមទារឱ្យមានការទទួលខុសត្រូវលើអំពើរបស់ខ្លួន ក៏ការទទួលខុសត្រូវនោះ មានចរិតលក្ខណៈខុសគ្នាពីការទទួលខុសត្រូវរបស់ឯកជន ។ ហេតុយ៉ាងដូច្នេះហើយ បានជាសាស្ត្រាចារ្យច្បាប់បារាំងល្បីល្បាញមួយរូប ឈ្មោះលោក

Jean Rivero បានសរសេរទុកថា " *នីតិរដ្ឋបាលជាសារព័ន្ធនៃវិធានគតិយុត្តទាំងឡាយណា ដែលប្លែកពីវិធានគតិយុត្តនៃ នីតិឯកជនដែលគ្រប់គ្រងសកម្មភាពរដ្ឋបាលនៃនីតិបុគ្គលសាធារណៈ*" ។

នៅក្នុងប្រទេសបារាំងសព្វថ្ងៃ គេឃើញមានសកម្មភាពរដ្ឋបាលរបស់រដ្ឋការកាន់តែច្រើនឡើងៗ ដែលស្ថិតនៅក្រោមវិធានគតិយុត្តនៃនីតិឯកជន ។ ហេតុដូចនេះហើយ នាពេលបច្ចុប្បន្ន គេមិនសូវគិតខ្វល់រឿងរកអត្ថន័យណាមួយឱ្យបានត្រឹមត្រូវ ១០០ ភាគរយនោះទេ ប៉ុន្តែ គេខំស្វែងរកថា វិធានគតិយុត្តណាខ្លះ ដែលជាវិធាននៃនីតិឯកជន អនុវត្តលើរឿងក្តីកើតឡើង ក្នុងសកម្មភាពរដ្ឋបាលរបស់នីតិបុគ្គលសាធារណៈ និងដែលជាសមត្ថកិច្ចរបស់តុលាការស៊ីវិល ។ ពីព្រោះជាធម្មតា តាមគោលការណ៍ច្បាប់បារាំង យុត្តាធិការដោះស្រាយរឿងក្តីរដ្ឋបាល ស្ថិតក្រោមតុលាការរដ្ឋបាល ដែលត្រូវបានបង្កើតឡើងដាច់ដោយឡែកពីតុលាការស៊ីវិល ។

នៅប្រទេសកម្ពុជាយើង សញ្ញាណនៃនីតិរដ្ឋបាលនេះ គឺមិនមានអ្វីខុសពីច្បាប់បារាំងនោះទេ ដោយប្រព័ន្ធច្បាប់កម្ពុជាទទួលឥទ្ធិពលជាយូរមកហើយ ពីប្រព័ន្ធច្បាប់បារាំង ជាពិសេសផ្នែកការគ្រប់គ្រង និងរៀបចំរដ្ឋបាលសាធារណៈនៃនីតិបុគ្គលសាធារណៈនេះ ។ ប៉ុន្តែ កម្ពុជាពុំមានតុលាការរដ្ឋបាលនោះទេ ដោយមាត្រា ១២៨ ថ្មី កថាខណ្ឌទី៣ នៃរដ្ឋធម្មនុញ្ញ បានចែងថា " អំណាចតុលាការគ្របដណ្តប់ទៅលើ រឿងក្តីទាំងអស់ រួមទាំងរឿងក្តីរដ្ឋបាលផង " ។ ដូច្នេះ យើងគ្មានបញ្ហាទំនាស់រឿងសមត្ថកិច្ចតុលាការឡើយ ប៉ុន្តែ យើងត្រូវដឹងថា វិធានគតិយុត្តណានៅក្រោមនីតិរដ្ឋបាល និងវិធានគតិយុត្តណាទៀតនៅក្រោមនីតិឯកជន ដើម្បីឱ្យចៅក្រមអនុវត្តច្បាប់ឱ្យបានត្រឹមត្រូវ ក្នុងការកាត់ក្តី ។

ជារួម យើងអាចកំណត់បានថា « នីតិរដ្ឋបាលសំដៅដល់សំណុំនៃវិធានគតិយុត្តទាំងឡាយ ដែលអនុវត្តលើរដ្ឋបាលសាធារណៈនៃនីតិបុគ្គលសាធារណៈ ធានាបាននូវការអនុវត្តបុព្វសិទ្ធិនៃអំណាចសាធារណៈ ដើម្បីប្រយោជន៍សាធារណៈ។ »

អត្ថបទទី២ : គោលការណ៍នីត្យានុកូលភាព

១- ហានានុក្រមធម្មនិយាមគតិយុត្តិ

ហានានុក្រមនៃវិធានគតិយុត្តិ គឺជាក្របខណ្ឌនីត្យានុកូលនៃកិច្ចការរបស់រដ្ឋបាលសាធារណៈ ។ វិធានដែលចេញពីប្រភពខ្ពស់ជាប្រភពធម្មនិយាមសម្រាប់វិធានដែលចេញពីប្រភពដែលស្ថិតនៅលំដាប់ទាបជាង ។ លំដាប់ថ្នាក់នេះចងគ្នា ជាហានានុក្រមនៃវិធានគតិយុត្តិ ។ រាល់កិច្ចរបស់រដ្ឋបាលសាធារណៈ ត្រូវតែស្ថិតនៅក្នុងក្របខណ្ឌនេះជាចាំបាច់ ដៀសវាងការធ្លាក់ចូលទៅក្នុងភាពខុសច្បាប់ ដែលតុលាការអាចនឹងប្រកាន់បាន ។

វិធានដែលចេញពីអំណាចនីតិបញ្ញត្តិ (ច្បាប់) គឺមានឋានៈខ្ពស់ជាងវិធានដែលចេញដោយនីតិប្រតិបត្តិ (បទបញ្ជា) ។ នៅក្នុងហានានុក្រមបទដ្ឋានគតិយុត្តិដែលមានប្រភពពីនីតិប្រតិបត្តិនោះ វិធានដែលចេញដោយថ្នាក់រាជរដ្ឋាភិបាល (ព្រះរាជក្រឹត្យ អនុក្រឹត្យ) ត្រូវមានឋានៈខ្ពស់ជាងវិធានដែលចេញដោយថ្នាក់ក្រសួង (ប្រកាស) និងថ្នាក់រដ្ឋបាលដែនដី (ដីកា) ។ កិច្ចរដ្ឋបាលជាបទបញ្ជា ត្រូវជាប្រភពនៃកិច្ចរដ្ឋបាលជាឯកត្តភូត ។

ហានានុក្រមធម្មនិយាមគតិយុត្តិនេះ អាចសង្ខេបតាមគំនូសបំព្រួញខាងក្រោម :

ច្បាប់ > ព្រះរាជក្រឹត្យ > អនុក្រឹត្យ > ប្រកាស > ដីកា

២- លក្ខខណ្ឌនីត្យានុកូលភាព

ក. នីត្យានុកូលភាពផ្ទៃក្រៅ

- វិធានសមត្ថកិច្ច

➢ សមត្ថកិច្ចតាមពេលវេលា : អាជ្ញាធររដ្ឋបាល មិនអាចប្រើអំណាចរបស់ខ្លួនបាន មុនពេលដែលខ្លួនបានចូលកាន់មុខតំណែងទេ ។ មានន័យថា អាជ្ញាធររដ្ឋបាលមិនអាចចេញសេចក្តីសម្រេច

ដែលមានឥទ្ធិពលមុនពេលចូលកាន់តំណែងជាផ្លូវការបានឡើយ ។ នៅពេលឈប់កាន់មុខតំណែង អាជ្ញាធរនោះក៏អស់សមត្ថកិច្ច ជាមួយគ្នាដែរ ។

- សមត្ថកិច្ចតាមទីកន្លែង : អាជ្ញាធររដ្ឋបាល អាចចេញសេចក្តីសម្រេចរដ្ឋបាលណាមួយ ដែលមានឥទ្ធិពលអនុវត្តតែក្នុងវង្វង់ទីកន្លែងនៃដែនសមត្ថកិច្ចរបស់ខ្លួនប៉ុណ្ណោះ (ឧ. វង្វង់សមត្ថកិច្ចត្រឹមព្រំដែននៃខេត្ត ឬ ស្រុកណាមួយជាក់លាក់ ជាដើម) ។
- សមត្ថកិច្ចតាមលំដាប់ថ្នាក់ : លំដាប់ថ្នាក់ចាត់តាំងនីមួយៗ ត្រូវមានសមត្ថកិច្ចកំរិតសមស្រប ទៅតាមលំដាប់ថ្នាក់នោះ ។ លំដាប់ថ្នាក់ណាធ្វើបានតែក្នុងវង្វង់សមត្ថកិច្ចថ្នាក់នោះ ដោយមិនត្រូវឆ្លងទៅធ្វើសមត្ថកិច្ចថ្នាក់ណាផ្សេងទៀត បានឡើយ ។ សមត្ថកិច្ចនេះ អាចហៅថា ជាសមត្ថកិច្ចតាមមុខការ ក៏បាន ។

- វិធានទម្រង់ : ក្រៅពីទម្រង់ជាព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងដីកា ដែលមាននៅក្នុងទំលាប់អនុវត្តរបស់រដ្ឋបាលសាធារណៈ ច្បាប់ខ្មែរ ពុំមានវិធានណាបង្ខំ ឱ្យត្រូវតែគោរពទម្រង់របៀបណា សរសេររបៀបណា សម្រាប់ការចេញលិខិតរដ្ឋបាល ឬការចេញការសម្រេចអ្វីមួយឡើយ ។ ការសម្រេចខ្លះ ធ្វើឡើងដោយផ្ទាល់មាត់ ឬ តាមកាយវិការផង ក៏បាន ។

- វិធាននីតិវិធី និងបែបបទ : នៅក្នុងការអនុវត្តចេញជាសេចក្តីសម្រេចរដ្ឋបាលផ្សេងៗ យើងអាចសង្កេតឃើញមាននីតិវិធី បីប្រភេទ គឺ :

  - *នីតិវិធីចំពោះមុខ* ដែលច្រើនសំដែង នូវគោលការណ៍នៃសិទ្ធិការពារខ្លួន ។
  - នីតិវិធីពិគ្រោះយោបល់ ដែលចេញពីគំនិតពីរធំៗ គឺគំនិតឱ្យមានការសម្របសម្រួលល្អប្រសើរ រវាងស្ថាប័នរដ្ឋបាល រវាងអាជ្ញាធរ ហើយនិងគំនិតឱ្យមានរចនាសម្ព័ន្ធចូលរួមពីប្រជាពលរដ្ឋ ក្នុងកិច្ចការរដ្ឋបាល ដើម្បីធ្វើការអភិវឌ្ឍសង្គម តាមលក្ខណៈលទ្ធិប្រជាធិបតេយ្យសេរី ។
  - *នីតិវិធីសហសេវិកភា* ដែលច្រើនប្រើចេញពីអង្គការសហសេវិកភា ដែលមានអំណាចសម្រេចជាក្រុម ដូចជា ក្រុមប្រឹក្សាឃុំ-សង្កាត់, ក្រុមប្រឹក្សាស្រុក ឬក្រុមប្រឹក្សាខេត្ត-រាជធានី ជាដើម ។

ខ. នីត្យានុកូលភាពផ្ទៃក្នុង

-*អំពីគោលដៅនៃច្បាប់* : គោលដៅ ជួនកាលមានចែងច្បាស់ ជួនកាលមិនមានចែងច្បាស់ ប៉ុន្តែចៅក្រមអាចរកឃើញ ដោយយោងទៅលើស្មារតីនៃច្បាប់ ។ ហេតុដូច្នេះ បានជាគេច្រើននិយាយថា " យោងតាម

អត្ថបទ ឬ យោងតាមស្មារតីនៃច្បាប់" ....។ ករណីដែល អាជ្ញាធររដ្ឋបាលប្រើអំណាច ដែលច្បាប់ ឬ បទបញ្ជា ប្រគល់ឱ្យខ្លួន ក្នុងគោលដៅផ្សេងពីគោលដៅដែលច្បាប់ ឬ បទបញ្ជានោះ បានកំណត់ គឺជាករណី" ការបន្លំអំណាច" ដែលនាំឱ្យសេចក្តីសម្រេចធ្វើឡើងនោះ អនីត្យានុកូល ។ ការបន្លំអំណាច មានពីរសណ្ឋាន គឺ ការបន្លំអំណាច ក្នុងគោលបំណងផលប្រយោជន៍ផ្ទាល់ខ្លួន និង ការបន្លំអំណាច ក្នុងគោលបំណងប្រយោជន៍ទូទៅ ដែលមិនមែនជាផលប្រយោជន៍ទូទៅដែលច្បាប់ ឬ បទបញ្ជាចង់សំដៅយក ។

-*អំពីកម្មវត្ថុនៃច្បាប់* : កម្មវត្ថុនៃច្បាប់ ឬ នៃបទបញ្ជា គឺរាល់បទប្បញ្ញត្តិទាំងឡាយ ដែលមានចែងក្នុងមាត្រានៃច្បាប់ ឬ នៃបទបញ្ជា ។ ការបំពានលើបទប្បញ្ញត្តិនោះ ជាការបំពានច្បាប់ ។ ការបំពានច្បាប់ គឺជាការបំពានវិធាន និងហានានុក្រមនៃច្បាប់ ដែលមានទិដ្ឋភាពពីរ : ការបំពានផ្ទាល់លើវិធានច្បាប់ ឬ ការបំពានមិនផ្ទាល់លើវិធានច្បាប់ ដែលអាចមានដូចជា ការភាន់ច្រឡំច្បាប់, ការភាន់ច្រឡំអង្គហេតុ ជាដើម ។

៣- អញ្ជត្រកម្មនៃគោលការណ៍នីត្យានុកូលភាព

ក. កាល:ទេស:ពិសេស

កាល:ទេស:ពិសេស គឺជាស្ថានភាពវិបត្តិដ៏ធំ ដែលកំហែងគំរាមដល់ផលប្រយោជន៍សាធារណៈ របស់ប្រទេសជាតិ ដល់និរន្តរភាពនៃដំណើរការសេវាកម្មសាធារណៈ ហើយដែលអាជ្ញាធររដ្ឋបាលពុំអាចទប់ទល់បាន បើសិនជាត្រូវស្ថិតជាប់ក្នុងនីត្យានុកូលភាពធម្មតា ។ ជាស្ថានការណ៍ ដែលបណ្តាលឱ្យរាជការ ព្យួរការអនុវត្តវិធានគតិយុត្តិធម្មតា ដោយប្រើនីត្យានុកូលភាពពិសេស ក្រោមការត្រួតពិនិត្យបច្ចាកាល របស់តុលាការ យ៉ាងតឹងតែង ។ កាល:ទេស:ពិសេស កម្រនឹងកើតមាន ដែលគេអាចរាប់បាន មានបីប្រភេទធំៗ គឺ :

- *សង្គ្រាម* ដូចជាសង្គ្រាមពិភពលោក ជាដើម ។
- *ព្រឹត្តិការណ៍ចលាចលសង្គម* ដូចជា ការបះបោរទ្រង់ទ្រាយធំ កូដកម្មទូទៅទូទាំងប្រទេស ដែលធ្វើឱ្យរាំងស្ទះការប្រព្រឹត្តទៅ នៃសេវាកម្មសាធារណៈ ។
- *មហន្តរាយធម្មជាតិ* ដូចជា បន្ទុះភ្នំភ្លើង ជាដើម ។

ដើម្បីពិចារណាលើទ្រឹស្តីកាល:ទេស:ពិសេសនេះ យើងពិនិត្យទៅលើ ផលវិស័យ បីយ៉ាង គឺ :

ទី១- អាជ្ញាធររដ្ឋបាល ក្នុងកាល:ទេស:ពិសេស អាចមិនគោរពវិធានគតិយុត្តិធម្មតាបាន ពីព្រោះ គេត្រូវប្រឈមមុខទល់នឹងស្ថានការណ៍ដ៏ធ្ងន់ធ្ងរ ឱ្យបានជោគជ័យ ជាដាច់ខាត ។ អ្នកគ្មានសមត្ថកិច្ចតាមច្បាប់ក៏អាចចាត់ការបាន ។ គេឈប់គិតគោរពបែបបទម្រង់ធម្មតាទាំងអស់ ។

ទី២- ប៉ុន្តែ រាជការត្រូវស្ថិតក្នុងនីងអ្វីដែលហៅថា"នីត្យានុកូលភាពនៃវិបត្តិ ឬ នីត្យានុកូលភាពពិសេស" ដែលមានលក្ខខណ្ឌ បីគឺ : គោលដៅការពារផលប្រយោជន៍សាធារណៈ, រយៈពេលនៃវិបត្តិដែលមិនត្រូវឱ្យហួសផុតវិបត្តិ, មធ្យោបាយដែលប្រើ ត្រូវឱ្យសមស្របនឹងស្ថានការណ៍ មិនឱ្យហួសហេតុ ។

ទី៣- ការទទួលខុសត្រូវរបស់រាជការ ក្នុងពេលនេះ គឺពុំមានអ្វីធ្ងន់ធ្ងរ ដូចក្នុងពេលធម្មតានោះទេ ។ កំហុសខ្លះ គេចាត់ទុកជាការត្រឹមត្រូវទៅវិញ ក្នុងកាលៈទេសៈពិសេស ។

<u>ការត្រួតពិនិត្យរបស់ចៅក្រម</u> : អំពើទាំងអស់ របស់អាជ្ញាធររដ្ឋបាល ដែលបានប្រព្រឹត្តក្នុងកាលៈទេសៈពិសេស ស្ថិតក្រោមការត្រួតពិនិត្យរបស់ចៅក្រម ។ លក្ខណៈនេះ ធ្វើឱ្យអាជ្ញាធររដ្ឋបាល ត្រូវនៅចំណុះនីត្យានុកូលភាព ដោយមិនអាចធ្វើអ្វីបានតាមចិត្តនោះទេ ។ ប៉ុន្តែ នៅក្នុងការអនុវត្តជាក់ស្តែង បញ្ហានៅតែមាន ពីព្រោះការត្រួតពិនិត្យបច្ឆាកាល មិនអាចទប់ស្កាត់ការរំលោភមិនឱ្យកើតមានឡើង បានឡើយ ។ អាជ្ញាធរដែលបានប្រព្រឹត្តរំលោភ ដោយសំអាងលេសថា ជាករណីនៃកាលៈទេសៈពិសេស ច្រើនតែមានហេតុផលដោះសាបាន ។ បើសិនជាគ្មានអ្នកប្តឹង អំពើល្មើសទាំងនោះនឹងស្ថិតនៅក្នុងនិទ្ទណ្ឌភាពជានិច្ច ។

ខ. រាជរដ្ឋាភិបាលកិច្ច

កិច្ចការរបស់រាជរដ្ឋាភិបាល មានពីរប្រភេទធំៗ គឺ : កិច្ចការរដ្ឋបាល និង កិច្ចការនយោបាយ ។

កិច្ចការរដ្ឋបាល គឺរាល់លិខិតស្តាម លិខិតបទដ្ឋាន និងរាល់ការងារគ្រប់គ្រងរដ្ឋបាលទាំងអស់ នៅក្នុងរចនាសម្ព័ន្ធ នៃស្ថាប័នទាំងឡាយដែលមាននៅក្នុងរដ្ឋាភិបាល ។ កិច្ចការរដ្ឋបាលទាំងនេះ ស្ថិតក្រោមនីតិរដ្ឋបាល ហើយជាពិសេស នៅក្នុងការត្រួតពិនិត្យនីត្យានុកូលភាពរបស់តុលាការ ។

កិច្ចការនយោបាយ គឺរាល់លិខិតស្តាម និងការងាររបស់រាជរដ្ឋាភិបាល ជាមួយនឹងអង្គការនីតិបញ្ញត្តិ អង្គការអន្តរជាតិ និងរដ្ឋអំណាចបរទេស ។ កិច្ចការនយោបាយនេះ ហៅថា " រាជរដ្ឋាភិបាលកិច្ច " ។ ច្បាប់ខ្មែរពុំមានចែងអំពីរាជរដ្ឋាភិបាលកិច្ចនៅឡើយទេ ។ រាជរដ្ឋាភិបាលកិច្ច មិននៅក្រោមចំណុះនីតិរដ្ឋបាល និងតុលាការនោះទេ ។ *រាជរដ្ឋាភិបាលកិច្ចមាន " អភ័យឯកសិទ្ធិយុត្តាធិការ"* ។

អត្ថបទទី៣ : ការរៀបចំរដ្ឋបាលសាធារណៈ

ការរៀបចំរដ្ឋបាលសាធារណៈ គឺធ្វើឡើងដោយអនុលោមទៅតាមគោលការណ៍ បីយ៉ាងគឺ មជ្ឈការ វិសហមជ្ឈការ និងវិមជ្ឈការ ។

១. គោលការណ៍ទូទៅ

មជ្ឈការ សំដៅដល់ការរៀបចំរដ្ឋបាលសាធារណៈ ដោយអំណាចរដ្ឋបាលទាំងអស់ប្រមូលផ្តុំ នៅលើរដ្ឋតែម្នាក់ឯង។ នៅក្នុងប្រព័ន្ធមជ្ឈការ មានតែរដ្ឋទេ ដែលមានអំណាចសម្រេច និងដាក់បទបញ្ជា ។ រដ្ឋប្រមូលផ្តុំអំណាចរដ្ឋបាលទៅនៅក្នុងអំណាចកណ្តាល ។ អំណាចកណ្តាល គឺអំណាចរដ្ឋបាលរបស់រដ្ឋាភិបាល ដែលកាន់កាប់ដោយនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការ ដែលជាប្រធានស្ថាប័នរដ្ឋ ។ អំណាចកណ្តាល ជាអំណាចរបស់រដ្ឋ ព្រោះរដ្ឋាភិបាល គឺតំណាងអំណាចគ្រប់គ្រងរដ្ឋ ដែលយើងហៅថា អំណាចនីតិប្រតិបត្តិ ។

វិសហមជ្ឈការ សំដៅដល់ការរៀបចំរដ្ឋបាលសាធារណៈ ដោយក្នុងនោះ គេមានវិធានការបែងចែកអំណាចកណ្តាល ឱ្យទៅភ្នាក់ងាររដ្ឋ ដែលនៅតាមទីកន្លែង ជាប់ជាមួយរាស្ត្រប្រជា ។ ការបែងចែកអំណាចកណ្តាល មិនមានន័យថា ជាការប្រគល់សិទ្ធិសម្រេចអ្វីៗ ដោយស្វ័យភាពនោះទេ ។ ការសម្រេច ដែលភ្នាក់ងាររដ្ឋទទួលបាន តាមការបែងចែក ស្របតាមគោលការណ៍វិសហមជ្ឈការនេះ គឺធ្វើតាមការបង្គាប់បញ្ជា ឬ តាមការកំណត់នៅលក្ខខណ្ឌឡាស់លាស់របស់អំណាចកណ្តាល ។

វិមជ្ឈការ សំដៅដល់ការរៀបចំរដ្ឋបាលសាធារណៈ ដែលក្នុងនោះ រដ្ឋមិនប្រមូលផ្តុំអំណាចរដ្ឋបាល តែម្នាក់ឯង ហើយទទួលស្គាល់ឱ្យសមូហភាពដែនដីផ្សេងទៀត មានអំណាចរដ្ឋបាលសម្រេចដោយស្វ័យភាព នូវរាល់កិច្ចការផង ទាំងឡាយ ដែលជាប្រយោជន៍ទូទៅរបស់រាស្ត្រប្រជានៅសមូហភាពដែនដីនោះផ្ទាល់ ។ ផលប្រយោជន៍រាស្ត្រទូទាំង ប្រទេស គឺជាផលប្រយោជន៍ជាតិ ដែលរដ្ឋមានតួនាទីជាអ្នកការពារ យ៉ាងមុតមាំបំផុត ។ គ្មានផលប្រយោជន៍ណាមួយ មានឧត្តមភាពលើផលប្រយោជន៍ជាតិបាននោះទេ នៅក្នុងប្រទេសនីមួយៗ ។ ផលប្រយោជន៍រាស្ត្រតាមទីកន្លែង ដូចជា តាម ឃុំ-សង្កាត់, ស្រុក-ក្រុង ឬខេត្ត-រាជធានី ជាដើម ជាផលប្រយោជន៍ផ្ទាល់សម្រាប់រាស្ត្រនៅទីកន្លែងនោះ សម្រាប់សង្គមតូចៗកំរិតនេះ ដែលតែងផ្សារភ្ជាប់ទៅនឹងជីវភាពប្រចាំថ្ងៃ ។ ផលប្រយោជន៍រាស្ត្រនៅតាមទីកន្លែង គឺ ផ្សេងពីប្រយោជន៍ជាតិទូទៅ ដែលពិបាកនឹងស្ថិតក្រោមការគ្រប់គ្រងឱ្យបានពិតប្រាកដ និងដិតដល់ពីរដ្ឋ ទោះបីមាន ការរៀបចំរដ្ឋបាលសាធារណៈ តាមគោលការណ៍វិសហមជ្ឈការក៏ដោយ ។ នៅក្នុងរដ្ឋទំនើប ដែលប្រកាន់យកលទ្ធិ ប្រជាធិបតេយ្យពិតប្រាកដ គេតែងទទួលស្គាល់ឱ្យមានការគ្រប់គ្រងផលប្រយោជន៍រាស្ត្រតាមទីកន្លែង ដោយរាស្ត្រខ្លួន ឯង។

ដើម្បីគ្រប់គ្រងទឹកដីប្រទេស ឱ្យបានគ្រប់ទីកន្លែង រដ្ឋត្រូវបែងចែកទឹកដីជា មណ្ឌលរដ្ឋបាល ។ នៅក្នុងរបប មជ្ឈការ មណ្ឌលរដ្ឋបាល គឺជារង្វង់សមត្ថកិច្ចតូចៗ ឬជាអំណាចកណ្តាលតាមទីកន្លែងរបស់រដ្ឋ ។ រដ្ឋត្រូវមានវត្តមាន នៅគ្រប់មណ្ឌលរដ្ឋបាលដែលមាន ។ ករណីដែលមណ្ឌលរដ្ឋបាល ទទួលបានអំណាចបែងពីអំណាចកណ្តាល មណ្ឌល រដ្ឋបាល នោះមានឈ្មោះថាជា មណ្ឌលរដ្ឋបាលវិសហមជ្ឈការ ដែលមានភ្នាក់ងាររដ្ឋទទួលអំណាចគ្រប់គ្រងរដ្ឋបាល បន្ត ពីរដ្ឋ ។ មណ្ឌលរដ្ឋបាល គ្មានបុគ្គលភាពគតិយុត្តនោះទេ ព្រោះពុំមែនជានីតិបុគ្គលសាធារណៈ ។ កិច្ចការទាំងឡាយ ដែលធ្វើក្នុងមណ្ឌលរដ្ឋបាល ជាកិច្ចការរដ្ឋទាំងអស់ ហើយធ្វើឡើងក្នុងនាមរដ្ឋ ។ នៅក្នុងរបបមជ្ឈការ ឬវិសហ-មជ្ឈការក៏ដោយ រដ្ឋគឺជានីតិបុគ្គលសាធារណៈ តែមួយគត់ ក្នុងប្រទេសទាំងមូល ។

ដោយឡែក នៅក្នុងរបបវិមជ្ឈការ ផលប្រយោជន៍រាស្ត្រតាមទីកន្លែង អាចនឹងគ្រប់គ្រងបានក្នុងរង្វង់ដែនដីមួយ ជា សមូហភាព ដែលហៅថា សមូហភាពដែនដី ឬ សមូហភាពតាមទីកន្លែង ។ សមូហភាពនេះ ជាទូទៅគឺប្រែក្លាយ

មកពីមណ្ឌលរដ្ឋបាល ឬ ត្រូវបានបង្កើតឡើងដោយឡែកពីមណ្ឌលរដ្ឋបាល។ ច្បាប់ទុកសមូហភាពដែនដី ជានីតិបុគ្គលសាធារណៈ ។ សមូហភាពនេះ មាននូវបុគ្គលភាពគតិយុត្ត ដោយមាននូវអំណាចស្វយ័ត មានទ្រព្យសម្បត្តិផ្ទាល់ មានធនធាន និងមូលធនផ្ទាល់ មានថវិកាផ្ទាល់ មានសិទ្ធិធ្វើពាណិជ្ជកម្ម ឧស្សាហកម្ម មានសិទ្ធិប្តឹងទៅតុលាការ ។ល។ ដូចនីតិបុគ្គលដទៃទៀតដែរ ។

២- ការរៀបចំរដ្ឋបាលសាធារណៈ

នៅក្នុងរដ្ឋទោល ដូចករណីព្រះរាជាណាចក្រកម្ពុជានេះ មិនអាចមានតែប្រព័ន្ធវិមជ្ឈការ ដោយអត់មានអំណាចកណ្តាលសោះនោះទេ ។ មណ្ឌលរដ្ឋបាលវិមជ្ឈការក្នុងរដ្ឋទោល មិនមានភាវិតវិមជ្ឈការរហូតដល់ទៅជា" រដ្ឋ" ដូចរដ្ឋសហព័ន្ធឡើយ ។ ក្នុងរបៀបរដ្ឋបាលសាធារណៈទំនើប គេរៀបចំឱ្យមានសហត្តិភាពល្អ រវាងអំណាចកណ្តាលរដ្ឋបាលវិសហមជ្ឈការ និងរដ្ឋបាលវិមជ្ឈការ ដោយលុបបំបាត់ការត្រួតពិនិត្យអាណាព្យាបាល ហើយជំនួសដោយការធ្វើសហការ និងការធ្វើសហប្រតិបត្តិការ ជួយគ្នាទៅវិញទៅមក ក្នុងគោលដៅវឌ្ឍនភាព និងអភិវឌ្ឍន៍ ។ ការវិវត្តន៍នៃការរៀបចំរដ្ឋបាលសាធារណៈនេះ តែងធ្វើជាតំណាក់កាល និងទៅតាមស្ថានភាពជាក់ស្តែងនៃរដ្ឋទោលនោះ ។

ក-រដ្ឋបាលរបស់រដ្ឋ

រដ្ឋតែងរៀបចំឱ្យមានរចនាសម្ពន្ធរដ្ឋបាល ដើម្បីជួយការងារអនុវត្តអំណាចរដ្ឋ រួមមាន រដ្ឋបាលសាធារណៈនៃអំណាចនីតិបញ្ញត្តិ, រដ្ឋបាលសាធារណៈនៃអំណាចនីតិប្រតិបត្តិ និងរដ្ឋបាលសាធារណៈនៃអំណាចតុលាការ ។ នៅក្នុងការអនុវត្ត រចនាសម្ព័ន្ធរដ្ឋបាលសាធារណៈ នៃអំណាចនីតិប្រតិបត្តិ មានលក្ខណៈស្មុកស្មាញ និងច្រើនជាងគេ អាស្រ័យដោយការងារ និងភាពចាំបាច់នៃការអនុវត្តអំណាចរដ្ឋនេះ ។ រដ្ឋាភិបាលដែលកាន់នូវអំណាចនីតិប្រតិបត្តិនេះ តែងរៀបចំរដ្ឋបាលសាធារណៈរបស់ខ្លួន ពីថ្នាក់ជាតិរហូតដល់ថ្នាក់ដែនដី នៅតាមមណ្ឌលរដ្ឋបាលនីមួយៗ ដែលច្បាប់សភាបានអនុញ្ញាតឱ្យ ។ នៅថ្នាក់ជាតិ ក្រៅពីស្ថាប័នរដ្ឋបាល ដែលតែងឃើញមាន ជាក្រសួង ឬរដ្ឋលេខាធិការ-

ដ្ឋាននោះ គេឃើញមានការបង្កើតជា គណៈកម្មការ គណៈកម្មាធិការ ក្រុមប្រឹក្សាជាតិ ឬ អាជ្ញាធរជាតិផ្សេងៗ ដើម្បីប្រសិទ្ធភាពនៃការងារ ។ នៅថ្នាក់ដែនដី តាមរយៈការបែងចែកអំណាច មណ្ឌលរដ្ឋបាល បានប្រែក្លាយទៅជា រដ្ឋបាលវិសហមជ្ឈការ ។

ខ-រដ្ឋបាលរបស់សមូហភាពដែនដី : ក្រុងសាធារណៈដែលគ្រប់គ្រង

តាមរយៈការអនុវត្តរបបវិមជ្ឈការនៅកម្ពុជា សមូហភាពដែនដី ដែលជានីតិបុគ្គលសាធារណៈ ត្រូវបានបង្កើតឡើង នៅតាមមណ្ឌលរដ្ឋបាលដែលមានស្រាប់ ដូចជា ឃុំ-សង្កាត់, ស្រុក-ក្រុង និងខេត្ត-រាជធានី ។ នៅតាមមូលដ្ឋានដែនដីនីមួយៗ យើងមានរដ្ឋបាលវិមជ្ឈការ បន្ថែមពីលើរដ្ឋបាលវិសហមជ្ឈការដែលមានស្រាប់ ។

គ-រដ្ឋបាលរបស់នីតិបុគ្គលសាធារណៈផ្សេងទៀត

តាមរយៈការអនុវត្តវិមជ្ឈការបច្ចេកទេស នីតិបុគ្គលសាធារណៈផ្សេងពីរដ្ឋ ត្រូវបានបង្កើតឡើង ដើម្បីទទួលបន្ទុកការងារគ្រប់គ្រងសេវាសាធារណៈ ។ នីតិបុគ្គលសាធារណៈនេះ មាននូវរចនាសម្ព័ន្ធរដ្ឋបាល ដោយឡែក ដើម្បីគ្រប់គ្រងការងាររបស់ខ្លួន ស្របតាមច្បាប់សភា និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងៗ ។

មេរៀនទី ៤ : សេចក្តីសំរេចរដ្ឋបាលផ្សេងៗ នៅព្រះរាជាណាចក្រកម្ពុជា

កថាខណ្ឌ ១ - រចនាសម្ព័ន្ធរដ្ឋបាលនៅកម្ពុជា

- ទាក់ទងនឹងការគ្រប់គ្រងរដ្ឋបាល :

ការគ្រប់គ្រងរដ្ឋបាលនៅកម្ពុជា គឺអនុវត្តតាមប្រព័ន្ធមជ្ឈការ-វិសហមជ្ឈការផង និង ប្រព័ន្ធវិមជ្ឈការផង។

ប្រព័ន្ធមជ្ឈការ-វិសហមជ្ឈការ គឺអនុវត្តពីថ្នាក់ជាតិ ទៅដល់ថ្នាក់មូលដ្ឋានដែនដី ដែលមានការបែងចែកតាមមាត្រា ១៤៥ថ្មី នៃរដ្ឋធម្មនុញ្ញ ១៩៩៣ :

រដ្ឋបាលថ្នាក់ជាតិមានពីរលំដាប់ថ្នាក់ គឺ លំដាប់ថ្នាក់រាជរដ្ឋាភិបាល និង លំដាប់ថ្នាក់ក្រសួង និង រដ្ឋលេខាធិការដ្ឋានស្វយ័ត។

រដ្ឋបាលថ្នាក់មូលដ្ឋានដែនដី គឺរាប់ពីថ្នាក់ខេត្ត ក្រុង ទៅត្រឹមថ្នាក់ ស្រុក ខ័ណ្ឌ។

ចំពោះការអនុវត្តន៍ប្រព័ន្ធវិមជ្ឈការ គឺធ្វើឡើងនៅថ្នាក់ឃុំ សង្កាត់ ដោយអនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ១៩ មិនា ២០០១។

- ទាក់ទងនឹងការគ្រប់គ្រងសេវាសាធារណៈ :

ការគ្រប់គ្រងសេវាសាធារណៈ អាចធ្វើឡើងតាមប្រព័ន្ធវិមជ្ឈការបច្ចេកទេស ដោយបង្កើតជាគ្រឹះស្ថានសាធារណៈ : ព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈគតិយុត្ត នៃគ្រឹះស្ថានសាធារណៈរដ្ឋបាល ចុះថ្ងៃទី ៣១ ធ្នូ ១៩៩៧ និង ច្បាប់ស្តីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ ចុះថ្ងៃទី ១៧ មិថុនា ១៩៩៦ ។

- ទាក់ទងនឹងអន្តរាគមន៍សេដ្ឋកិច្ចរបស់រដ្ឋ :

រដ្ឋបង្កើតជា សហគ្រាសសាធារណៈ ដែលអាចមានរូបរាងជា គ្រឹះស្ថានសាធារណៈមានលក្ខណៈពាណិជ្ជកម្ម និង ឧស្សាហកម្ម ជាក្រុមហ៊ុនរដ្ឋ និង ជាក្រុមហ៊ុនចំរុះ : ច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ ។

- រដ្ឋបាលធនាគារជាតិ ឬ ធនាគារកណ្តាល : ច្បាប់ស្តីពីការរៀបចំ និង ប្រព្រឹត្តនៃធនាគារជាតិ ចុះថ្ងៃ ទី ២៦ មករា ១៩៩៦ ។

កថាខណ្ឌ ២ - សេចក្តីសំរេចរដ្ឋបាល និង អាជ្ញាធរមានសមត្ថកិច្ច

២.១ - សេចក្តីសំរេចបទបញ្ជា ឬ អំណាចចេញបទបញ្ជា

លិខិតជាបទបញ្ជា គឺជាសេចក្តីសំរេចរដ្ឋបាលទាំងអស់ ផ្សេងពីសេចក្តីសំរេចឯកត្តភូត។ សេចក្តីសំរេចឯកត្តភូត គឺសំដៅទៅលើសេចក្តីសំរេចដែលមានចង្អុលបង្ហាញចំឈ្មោះនៃអ្នកទទួលសេចក្តីសំរេច ឬ អ្នកដែលត្រូវអនុវត្តលិខិត ដែលជារូបវន្តបុគ្គល ឬ នីតិបុគ្គលឯកជន ឬសាធារណៈ។ ឧទាហរណ៍: សេចក្តីសំរេចយល់ព្រម ឬ បដិសេធការអនុញ្ញាត ដែលធ្វើឡើងដោយអាជ្ញាធររដ្ឋបាលចំពោះបុគ្គលណាម្នាក់ គឺជាសេចក្តីសំរេចឯកត្តភូត។ ដូចគ្នានេះដែរ លិខិតតែងតាំង ឬ ដំឡើងឋានន្តរសក្តិមន្ត្រីរាជការនៅក្នុងមុខងារសាធារណៈ គឺមានលក្ខណៈជាសេចក្តីសំរេចឯកត្តភូត។

គួរបញ្ជាក់ថាក្នុងការអនុវត្តន៍ជាក់ស្តែង អាជ្ញាធររដ្ឋបាលអាចចេញទាំងលិខិតជាបទបញ្ជា និង ទាំង សេចក្តីសំរេចឯកត្តភូត។

- លក្ខណៈទូទៅនៃអំណាចចេញបទបញ្ជាមានច្រើនយ៉ាងដែលក្នុងនោះសំខាន់ៗមានដូចជា :

- *មិនមានអំណាចចេញបទបញ្ជាទេ ប្រសិនបើគ្មានអត្ថបទគតិយុត្តកំណត់*

ជាគោលការណ៍ អាជ្ញាធររដ្ឋបាលមួយមិនមានអំណាចចេញបទបញ្ជាទេ ប្រសិនបើគ្មានអត្ថបទគតិយុត្តណាមួយផ្តល់អំណាចនេះឱ្យទេ។ អត្ថបទគតិយុត្តនេះអាចជា រដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ... ។ ជាញឹកញាប់ គឺច្បាប់ជាអ្នកកំណត់ពីលក្ខន្តិកៈនៃស្ថាបន័មួយ និង អំណាចរបស់ថ្នាក់ដឹកនាំ នៃស្ថាបន័ទាំងនោះ ។

គោលការណ៍នេះមានករណីលើកលែងពីរយ៉ាងគឺ : ចំពោះនាយករដ្ឋមន្ត្រី ទោះបីជាមិនមានអត្ថបទច្បាប់ប្រទានសិទ្ធិអំណាចក៏ដោយ ក៏នៅតែមានអំណាចចាត់ជាវិធានការប៉ូលីសផ្សេងៗ អាចអនុវត្តបានទូទាំងប្រទេស។ រីឯប្រធានស្ថាប័ននីមួយៗវិញក៏មានអំណាចចាត់ជាវិធានការចាំបាច់ផ្សេងៗ សំរាប់ធានា ដល់ដំណើរការល្អរបស់រដ្ឋបាលដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួនផងដែរ ទោះបីជាមិនមានច្បាប់កំណត់ជាមុនក៏ដោយ។

គោលការណ៍ខាងលើ ក៏ត្រូវបានគេយកមកអនុវត្តចំពោះអាជ្ញាធរមូលដ្ឋានវិមជ្ឈការ។ អាជ្ញាធរវិមជ្ឈការមានអំណាចចេញបទបញ្ជាដោយសេរី ចំពោះប្រជាពលរដ្ឋដែលរស់នៅក្នុងមូលដ្ឋានដែនដីរបស់ខ្លួន។ អំណាចចេញបទបញ្ជាដោយសេរីនេះក៏ចាំបាច់ស្ថិតនៅក្នុងក្របខ័ណ្ឌនៃច្បាប់ដែរ។

- *ការប្រើប្រាស់អំណាចចេញបទបញ្ជា គឺជាកាតព្វកិច្ច*

នៅពេលណាដែលអាជ្ញាធររដ្ឋបាលណាមួយមានអំណាចចេញបទបញ្ជា អាជ្ញាធររដ្ឋបាលនោះមានកាតព្វកិច្ចប្រើប្រាស់វា។ ការអាក់ខានមិនបានប្រើប្រាស់អំណាចនេះ អាចក្លាយទៅជាការខុសច្បាប់ ដែលនាំឱ្យមានការទទួលខុសត្រូវរបស់រដ្ឋបាល។

នេះមានន័យថា រដ្ឋាភិបាល និង រដ្ឋបាល មានកាតព្វកិច្ចចេញជាបទបញ្ជាសំរាប់អនុវត្តច្បាប់ទាំងឡាយដែលអនុម័តដោយរដ្ឋសភា ឬ សំរាប់បំពេញបន្ថែមបទបញ្ជា ដែលការអនុវត្តន៍បទបញ្ជាទាំងនេះទាមទារឱ្យមាន ការចេញបទបញ្ជាផ្សេងៗទៀត។ ឧទាហរណ៍: ព្រះរាជក្រឹត្យមួយចំនួនក្រោយពេលចេញហើយតម្រូវឱ្យមានអនុក្រឹត្យ ប្រកាស បន្ថែមទៀតទើបអាចអនុវត្តបានពេញលក្ខណៈ។ ការចេញបទបញ្ជាសំរាប់ការអនុវត្តន៍នេះ មិនចាំបាច់ត្រូវតែធ្វើភ្លាមៗនោះទេ គឺអាចធ្វើឡើងក្នុងពេលវេលាមួយដ៏សមស្របដោយផ្អែកទៅតាម កាលៈទេសៈជាក់ស្តែងនិមួយៗ។

ទាំងអស់នេះគឺជាហេតុផលធម្មតា សម្រាប់ការអនុវត្តន៍របបប្រជាធិបតេយ្យ ដែលចង់ទប់ស្កាត់មិនឱ្យអំណាចរដ្ឋបាលធ្វើការរាំងស្ទះ ដល់ដំណើរការអនុវត្តន៍នៃច្បាប់ដែលអនុម័តដោយសភា។

ទន្ទឹមនឹងនេះដែរ រដ្ឋាភិបាលនិងរដ្ឋបាលក៏មានកាតព្វកិច្ចធ្វើនិរាករណ៍ចំពោះបទបញ្ជាទាំងឡាយណាដែលខុសច្បាប់។ បទបញ្ជាដែលខុសច្បាប់នេះអាចកើតមានឡើងតាំងពីដំបូង ឬ បន្ទាប់ពីមានការផ្លាស់ប្តូរ

ស្ថានភាពច្បាប់ ឬ ហេតុការណ៍ក្រោយមក។ ភាពភ្ជាប់ចិត្តលុបចោលបទបញ្ជាខុសច្បាប់នេះ ត្រូវតែបំពេញ ទោះជាគ្មានការស្នើសុំទៅរដ្ឋបាលក៏ដោយ។

-ប្រភេទនៃអំណាចចេញបទបញ្ជា :

. អំណាចចេញបទបញ្ជាទូទៅ (General regulation power)

នៅប្រទេសបារាំង អំណាចចេញបទបញ្ជាទូទៅត្រូវបានគេប្រគល់ទៅឱ្យប្រធានាធិបតី និង នាយករដ្ឋមន្ត្រី។ ចំណែកនៅប្រទេសកម្ពុជាយើងវិញ ដោយព្រះមហាក្សត្រជាប្រមុខរដ្ឋដែលមិនកាន់អំណាច (មាត្រា ៧ នៃរដ្ឋធម្មនុញ្ញ) អំណាចចេញបទបញ្ជាទូទៅនេះត្រូវបានរ៉ាប់រងដោយនាយករដ្ឋមន្ត្រីតែម្នាក់ឯង និងមានការចូលរួមខ្លះពីព្រះមហាក្សត្រដែរនៅពេលមានសំណើសុំពីរដ្ឋាភិបាល។

- អំណាចចេញបទបញ្ជាទូទៅរបស់នាយករដ្ឋមន្ត្រី

រដ្ឋធម្មនុញ្ញប្រទេសបារាំង មាត្រា ២១ កំណត់ថា "ជាគោលការណ៍ នាយករដ្ឋមន្ត្រីមានអំណាចចេញ បទបញ្ជាទូទៅ"។ ប្រទេសកម្ពុជាក៏មានលក្ខណៈដូចគ្នាដែរ អំណាចចេញបទបញ្ជាទូទៅរបស់នាយករដ្ឋមន្ត្រី ស្តែង ចេញតាមរូបភាពបីយ៉ាងគឺ :

- អំណាចចេញបទបញ្ជាសំរាប់អនុវត្តច្បាប់ ឬអំណាចចេញបទបញ្ជាប្រទាន :

វាគឺជាការចេញបទបញ្ជាចាំបាច់សម្រាប់ការអនុវត្តច្បាប់ ដែលអនុម័តឡើងដោយសភា។ នៅ ប្រទេសបារាំងនាយករដ្ឋមន្ត្រីអាចផ្តួចផ្តើម តាមគំនិតខ្លួនឯងផ្ទាល់ ឬទៅតាមការកំណត់នៃច្បាប់ក្នុងការចេញ ជាក្រឹត្យសំរាប់ការអនុវត្តន៍ច្បាប់។ តែនៅប្រទេសកម្ពុជា នាយករដ្ឋមន្ត្រីអាចចេញ បទបញ្ជាសំរាប់អនុវត្តច្បាប់ តាមរយៈ"អនុក្រឹត្យ" តែទៅតាមការចង្អុលបង្ហាញដោយច្បាប់របស់សភា ប៉ុណ្ណោះ។ មានច្បាប់ជាច្រើនដែលអនុម័តដោយសភា ដែលបានកំណត់ទុកជាមុនពីការចេញអនុក្រឹត្យសំរាប់ អនុវត្តច្បាប់ទាំងនេះ។

ក្នុងការប្រើប្រាស់អំណាចចេញបទបញ្ជាប្រទាន នាយករដ្ឋមន្ត្រីត្រូវគោរពច្បាប់ ដែលជាអ្នកកំណត់ឱ្យចេញបទបញ្ជាសំរាប់អនុវត្តនេះ។ បទបញ្ជាដែលចេញ មិនត្រូវមានខ្លឹមសារផ្ទុយពីគោលការណ៍ទាំងឡាយរបស់ច្បាប់ ឬហួសពីអ្វីដែលជាការអនុញ្ញាត និងជាការចាំបាច់សំរាប់ការអនុវត្តន៍ច្បាប់នោះទេ។

- អំណាចចេញបទបញ្ជាស្វយ័ត:

អំណាចចេញបទបញ្ជាស្វយ័តរបស់នាយករដ្ឋមន្ត្រីនៅប្រទេសបារាំង មានកំណត់យ៉ាងច្បាស់នៅក្នុងរដ្ឋធម្មនុញ្ញឆ្នាំ ១៩៥៨។ យោងតាមមាត្រា ៣៧ នៃរដ្ឋធម្មនុញ្ញបារាំង "វិធានការ ឬកិច្ចការទាំងឡាយណាដែលមិនបម្រុងទុកសម្រាប់សភាដោយរដ្ឋធម្មនុញ្ញទេ គឺអាចធ្វើឡើងដោយបទបញ្ជារបស់នាយករដ្ឋមន្ត្រី..." ។

នៅប្រទេសកម្ពុជា យោងតាមមាត្រា ១ វាក្យខ័ណ្ឌទី ២ នៃព្រះរាជក្រមលេខ ០២ ន.ស ៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី "រាជរដ្ឋាភិបាល (...) ដឹកនាំកិច្ចការទូទៅរបស់ រដ្ឋ លើកលែងតែកិច្ចការអ្វីដែលជាសមត្ថកិច្ចរបស់អង្គការនីតិបញ្ញត្តិ និង អង្គការតុលាការ"។ តាមរយៈមាត្រានេះ នាយករដ្ឋមន្ត្រីដែលជាប្រមុខនៃរាជរដ្ឋាភិបាល អាចចេញជាអនុក្រឹត្យដើម្បីដឹកនាំកិច្ចការទូទៅរបស់រដ្ឋ"។

អំណាចចេញបទបញ្ជាស្វយ័តដោយអនុក្រឹត្យនេះ មិនត្រូវមានខ្លឹមសារផ្ទុយ ឬ ប៉ះពាល់ដល់វិស័យរបស់ច្បាប់នោះទេ។ វិស័យច្បាប់ដែលកំណត់ដោយរដ្ឋធម្មនុញ្ញមានដូចជា : *ក្រុមប្រឹក្សារាជសម្បត្តិ (មាត្រា ១៣ ថ្មី) ខុត្តមក្រុមប្រឹក្សាការពារជាតិ (មាត្រា ២៤ ថ្មី) ហ៊ានន្តរសត្តិ ហ៊ាន: យោធា និងស៊ីវិល (មាត្រា ២៩) សិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ (មាត្រា ៣១) សិទ្ធិទទួលការធានារ៉ាប់រងសង្គម និងអត្ថប្រយោជន៍ខាងសង្គមកិច្ច (មាត្រា ៣៦) សិទ្ធិធ្វើកូដកម្ម និងធ្វើបាតុកម្ម (មាត្រា ៣៧) សិទ្ធិបង្កើតសមាគម និង គណៈបក្សនយោបាយ (មាត្រា ៤២) សញ្ជាតិខ្មែរ បត្យាប័ន ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ (មាត្រា ៧៦) ការបោះឆ្នោតជ្រើសរើសសមាជិកព្រឹទ្ធសភា (មាត្រា ១០ថ្មី) ការរៀបចំ និង ការប្រព្រឹត្តទៅនៃសហជីព (មាត្រា ៣៦) ការរ៉ាប់រងមិនឱ្យមានការរំលោភបំពានរូបរាងកាយបុគ្គល ការការពារជីវិត កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ប្រជាពលរដ្ឋ ការចាប់ខ្លួន ការឃាត់ខ្លួន ការឃុំខ្លួន (មាត្រា ៣៨) ការឆែកឆេរលំនៅដ្ឋានសំភារ: វត្ថុ និងរូបកាយ (មាត្រា ៤០) របបសារពត៌មាន (មាត្រា ៤១) កម្មសិទ្ធិឯកជន (មាត្រា*

៤៤) ទ្រព្យសម្បត្តិសាធារណៈ (មាត្រា៥០) ទ្រព្យសម្បត្តិរដ្ឋ (មាត្រា ៥៨) កាតព្វកិច្ចការពារមាតុភូមិ (មាត្រា ៤៩) ការរៀបចំ និង ការប្រព្រឹត្តទៅនៃប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ (មាត្រា ៥៦) ការយកពន្ធដារ ការគ្រប់គ្រងរូបិយវត្ថុ និងប្រព័ន្ធហិរញ្ញវត្ថុ (មាត្រា ៥៧) ការតម្រូវឱ្យលក់ផលិតផលជូនរដ្ឋ ការយកកោគផល ការយកទ្រព្យសម្បត្តិឯកជនទៅប្រើប្រាស់ (មាត្រា ៦០) ថវិកាជាតិ ការបង្កើនពន្ធដារ ខ្ចីប្រាក់រដ្ឋ រដ្ឋខ្ចីប្រាក់ កិច្ចសន្យាហិរញ្ញវត្ថុ គណនីរដ្ឋបាល (មាត្រា ៥០ ថ្មី) ការលើកលែងទោសជាទូទៅ សន្ធិសញ្ញា អនុសញ្ញាអន្តរជាតិ ការប្រកាសសង្គ្រាម (មាត្រា ៥០ ថ្មី) ការរៀបចំសមាជរដ្ឋសភា និងព្រឹទ្ធសភា (មាត្រា ១១៧ ថ្មី) ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី (មាត្រា ១២៧ ថ្មី) ការបង្កើតឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម (មាត្រា ១៣៤ថ្មី) លក្ខន្តិកៈចៅក្រម និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ (មាត្រា ១៤៤ ថ្មី) ការគ្រប់គ្រងរដ្ឋបាល ខេត្តក្រុង ស្រុក ខ័ណ្ឌ ឃុំ និងសង្កាត់ (មាត្រា ១៤៦ ថ្មី) ការរៀបចំសមាជិកជាតិ (មាត្រា ១៤៩ថ្មី) និងការបង្កើតក្រសួង និងរដ្ឋលេខាធិការដ្ឋាន (មាត្រា ៣នៃព្រះរាជ ក្រមលេខ ០២. នស. ៩៤)។

វិស័យរបស់ច្បាប់ដែលបានរៀបរាប់ខាងលើ គឺគេមិនអាចធ្វើឡើងដោយអនុក្រឹត្យដោយគ្មានយោងទៅលើច្បាប់ក្នុងវិស័យនោះបានឡើយ។

- អំណាចចេញបទបញ្ជាប៉ូលីស:

ដូចគ្នានេះដែរ ក្នុងឋានៈជាប្រមុខរាជរដ្ឋាភិបាល នាយករដ្ឋមន្ត្រីមានអំណាចចេញបទបញ្ជាប៉ូលីសសំរាប់ គ្រប់គ្រង រៀបចំ និង ធានានូវសណ្តាប់សាធារណៈ ដែលមានអានុភាពអនុវត្តបានទូទាំងប្រទេស។

- អំណាចចេញបទបញ្ជាទូទៅរបស់ប្រមុខរដ្ឋ

ប្រធានាធិបតីប្រទេសបារាំង ចូលរួមក្នុងការប្រើអំណាចចេញបទបញ្ជាទូទៅ ដោយសារការចុះហត្ថលេខាលើ "ក្រឹត្យ" ដែលពិភាក្សាដោយក្រុមប្រឹក្សារដ្ឋមន្ត្រី និង លើ "ក្រឹត្យ-ច្បាប់" ឬ "បញ្ញត្តិ" ដែលកំណត់ដោយមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញបារាំង។

ដោយឡែកនៅប្រទេសកម្ពុជា ដោយព្រះមហាក្សត្រពុំមានអំណាចដូចប្រធានាធិបតីប្រទេស បារាំងនោះ ទ្រង់មានព្រះរាជសិទ្ធត្រឹម "ឡាយព្រះហស្តលេខាលើព្រះរាជក្រឹត្យ តែទៅតាមសេចក្តីស្នើសុំពីគណៈរដ្ឋមន្ត្រី ប៉ុណ្ណោះ" (មាត្រា ២៨ ថ្មីនៃរដ្ឋធម្មនុញ្ញ) ។

. **អំណាចចេញបទបញ្ជាពិសេស** (Special regulation power)

ទន្ទឹមនឹងអំណាចចេញបទបញ្ជាទូទៅខាងលើ គេឃើញមានអំណាចចេញបទបញ្ជាពិសេសជាច្រើនទៀត ដែលត្រូវបានគេប្រគល់ទៅឱ្យអាជ្ញាធររដ្ឋបាល ។ អំណាចចេញបទបញ្ជាពិសេសនេះពាក់ព័ន្ធទៅនឹងកិច្ចការ ឬ កម្មវត្ថុ ឬ ភូមិសាស្ត្រមួយជាក់លាក់ ។

រដ្ឋមន្ត្រីមានអំណាចចេញបទបញ្ជាពិសេស ទៅតាមការកំណត់របស់ច្បាប់ ។ មាត្រា ២៩ នៃ ច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រីចែងថា " ប្រធានស្ថាប័ន (រដ្ឋមន្ត្រី / រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានស្ម័យត) មានសិទ្ធិចេញបទបញ្ជាដោយប្រកាស ។ ប្រកាសរបស់ស្ថាប័នមិនអាចចែងអំពីកិច្ចការអ្វី ដែលមិនចូលក្នុងវង្វង់ក្របខ័ណ្ឌសមត្ថកិច្ចនៃស្ថាប័នឡើយ ហើយក៏ពុំអាចមានទំនាស់ជាមួយលិខិត បទដ្ឋាននានាដូចជា អនុក្រឹត្យ ឬ សារាចររបស់រាជរដ្ឋាភិបាលដែរ "។

អំណាចចេញបទបញ្ជាពិសេស ក៏ត្រូវបានគេប្រគល់ទៅអោយអាជ្ញាធររដ្ឋបាលមួយចំនួនដូចជា ក្រៈស្ថានសាធារណៈរ៉ាប់រងសេវាសាធារណៈថ្នាក់ជាតិ គណៈវិជ្ជាជីវៈ វិក្រុមហ៊ុនឯកជនដែលទទួលបន្ទុកសេវាសាធារណៈ ផ្សេងៗ... ។ អាជ្ញាធររដ្ឋបាលវិមជ្ឈការមូលដ្ឋាន ក៏មានអំណាចចេញបទបញ្ជាពិសេសនៅក្នុងក្របខ័ណ្ឌនៃដែនដីរបស់ ខ្លួនដែរ ។

២.២ - សេចក្តីសំរេចឯកត្តភូត

សេចក្តីសំរេចឯកត្តភូត អាចចេញឡើងដោយអាជ្ញាធររដ្ឋបាលក្នុងគ្រប់វិស័យ តែយើងសង្កេតឃើញ មានច្រើនក្នុងវិស័យមុខងារសាធារណៈ ជាពិសេសទាក់ទងនឹង ការតែងតាំងមន្ត្រីរាជការ និង ការដាក់អោយចូលនិវត្តន៍។

សេចក្តីសំរេចឯកត្តភូតដទៃទៀត ចេញឡើងក្រោមរូបភាពជា ប្រកាសអនុញ្ញាត ឬ ដីកាអនុញ្ញាត ផ្សេងៗ ដែលអាចហៅជារួមថា " លិខិតអនុញ្ញាតរដ្ឋបាល "។ ជាទូទៅ លិខិតអនុញ្ញាត គឺជាសេចក្តីសំរេចរដ្ឋបាលឯកត្តភូត ដែលអាចចេញឡើងដោយអាជ្ញាធររដ្ឋបាលគ្រប់ជាន់ថ្នាក់ ប៉ុន្តែអាស្រ័យជាចាំបាច់ទៅតាមសេចក្តីសំរេចបទបញ្ជ ឬ ច្បាប់ដែលជាប្រភពធម្មនិយាម។ សេចក្តីសំរេចឯកត្តភូត ក៏អាចមានលក្ខណៈជាសេចក្តីសំរេចបដិសេធផងដែរ។ ជាធម្មតា គឺមានតែសេចក្តីសំរេចឯកត្តភូតប៉ុណ្ណោះ ដែលជាកម្មវត្ថុនៃបណ្តឹងផ្នែករដ្ឋបាល ព្រោះវាមានផលប៉ះពាល់ដោយផ្ទាល់ទៅបុគ្គលណាម្នាក់។

សេចក្តីសំរេចឯកត្តភូត អាចមានទំរង់ពីរបែប : សេចក្តីសំរេចមានទំរង់ច្បាស់លាស់ និងសេចក្តីសំរេចដោយស្ងាត់ស្ងៀម។

កថាខណ្ឌ ៣ - សារាចរ និង លិខិតរដ្ឋបាលដែលមិនមែនជាសេចក្តីសំរេច

ក. សារាចរ

"...សារាចរ ជាអត្ថបទសំរាប់បំភ្លឺកិច្ចការ និងធ្វើការណែនាំ ។..." (មាត្រា ២៩ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី)។

ផ្អែកតាមមាត្រានេះ "សារាចរ" គឺគ្រាន់តែជាអត្ថបទបំភ្លឺកិច្ចការ ឬធ្វើការណែនាំប៉ុណ្ណោះ មិនមែនជាអត្ថបទគតិយុត្ត ដែលគេអាចយកទៅប្រើប្រាស់ ឬប្តឹងផ្តល់នៅចំពោះមុខតុលាការបានឡើយ ។ "សារាចរ" ជាវិធានរដ្ឋបាលផ្ទៃក្នុងរបស់រាជការ ដែលមានគោលដៅបំភ្លឺចំណុចខ្លះនៃអត្ថបទច្បាប់ ឬនៃបទបញ្ជា ដែលធ្វើឡើង ដោយប្រធានស្ថាប័ន ក្នុងគោលបំណងឱ្យមានការយល់ច្បាស់ និងឱ្យមានការអនុវត្តឱ្យបានដូចៗគ្នា ដោយភ្នាក់ងារ សាធារណៈ ដែលស្ថិតនៅក្រោមបង្គាប់របស់ខ្លួន ។

សារាចរប្រភេទនេះ នៅក្នុងច្បាប់បារាំង គេហៅថា "សារាចរបកស្រាយ" ។ ប្រជាពលរដ្ឋគ្មានសិទ្ធប្តឹងរំលាយចោល "សារាចរបកស្រាយ" ឬក៏យកមកសំអាងក្នុងរឿងក្តីរបស់ខ្លួននៅចំពោះមុខតុលាការបាននោះទេ ។ ព្រោះថា វាគ្រាន់តែជាវិធានរដ្ឋបាលសំរាប់កិច្ចការផ្ទៃក្នុងរបស់រាជការតែប៉ុណ្ណោះ គឺមិនមែនសំរាប់សាធារណៈជនទេ ។

សារាចរអាចចេញឡើងដោយរាជរដ្ឋាភិបាល នាយករដ្ឋមន្ត្រី និងសមាជិករាជរដ្ឋាភិបាលដែលជាប្រធានស្ថាប័ន ។ សារាចរ ដែលធ្វើឡើងដោយសមាជិករាជរដ្ឋាភិបាល ដែលជាប្រធានស្ថាប័ន មានរូបភាពជា "សារាចរក្រសួង" ឬ "សារាចរអន្តរក្រសួង" (ប្រសិនបើវាជាសារាចរួមរបស់ក្រសួង ចាប់ពីចំនួនពីរក្រសួងឡើងទៅ) ។

<u>ចំណាំ</u> :

សារាចរខ្លះអាចមានលក្ខណៈបទបញ្ជ : ប្រភេទសារាចរនេះ អាចធ្វើអោយមានការប្រែប្រួលស្ថានភាពគតិយុត្តិព្រោះ វាផ្តល់ជាសិទ្ធិ ឬជាការធានាថ្មីដល់ប្រជាពលរដ្ឋ ឬ បង្កើតជាវិធានដែលមានលក្ខណៈបទបញ្ជ បន្ថែមទៅលើបទដ្ឋានមុន។

ខ. លិខិតរដ្ឋបាលដែលមិនមានលក្ខណៈជាសេចក្តីសំរេច

ក្រៅពីសារាចរ លិខិតឯកតោភាគី ដែលត្រូវបានគេចាត់ទុកថាមិនមែនជាសេចក្តីសំរេចរដ្ឋបាល អាចមានជាច្រើនដូចជា : វិធានរដ្ឋបាលផ្ទៃក្នុង សំរួមពរ និងការងារផ្សេងៗទៀត ដែលពាក់ព័ន្ធនឹងការរៀបចំសេចក្តីសំរេចរដ្ឋបាល។

. សេចក្តីបង្គាប់របស់ក្រសួង

នៅក្នុងច្បាប់បារាំង វាជាលិខិតឯកតោភាគីមួយប្រភេទ ដែលមានលក្ខណៈស្រដៀងគ្នា នឹងសារាចរដែរ ព្រោះអាជ្ញាធររដ្ឋបាលថ្នាក់លើចេញសេចក្តីពន្យល់បំភ្លឺអត្ថបទច្បាប់ ឬបទបញ្ជា ប៉ុន្តែមានបង្គាប់ឱ្យភ្នាក់ងារសាធារណៈនៅក្រោមឱវាទគោរពតាម ។ "សេចក្តីបង្គាប់របស់ក្រសួង" មិនមានអនុភាពគតិយុត្ត

ចំពោះ ប្រជាពលរដ្ឋឡើយព្រោះវាជាវិធានការសំរាប់កិច្ចការផ្ទៃក្នុងរបស់រដ្ឋបាលប៉ុណ្ណោះ ។ រាស្ត្រប្រជាពុំអាចប្តឹងទៅតុលាការដើម្បីលុប "សេចក្តីបង្គាប់របស់ក្រសួង"នេះបានទេ ។

. *សេចក្តីណែនាំកំណត់ទិសដៅ*

គឺសំដៅទៅលើបទប្បញ្ញត្តិចេញដោយអាជ្ញាធររដ្ឋបាល ដែលប្រើអំណាចឆន្ទានុសិទ្ធិដើម្បីដាក់លក្ខណៈវិនិច្ឆ័យផ្សេងៗសំរាប់សេចក្តីសំរេចរបស់ខ្លួន ដោយរក្សាសិទ្ធិក្នុងការកែប្រែបានក្នុងករណីចាំបាច់ជាយថាហេតុ ។ ឧ.: រដ្ឋមន្ត្រីក្រសួងមួយ ចេញសេចក្តីណែនាំកំណត់ទិសដៅមួយ ដោយមានកម្មវិត្តុដាក់លក្ខខណ្ឌចំពោះការផ្តល់ប្រាក់ឧបត្ថម្ភ ប៉ុន្តែរក្សាលទ្ធភាពដើម្បីផ្តល់ប្រាក់ឧបត្ថម្ភទាំងនេះចំពោះសហគ្រាសណាមួយដែលមិនបានបំពេញលក្ខខណ្ឌខាងលើបាន ប្រសិនបើជាផលប្រយោជន៍ទូទៅតម្រូវថាគួរតែផ្តល់ឱ្យ ។

"សេចក្តីណែកំណត់ទិសដៅ" គឺជាកំណត់ទិសដៅដោយអាជ្ញាធររដ្ឋបាលខ្លួនឯងសំរាប់ធ្វើសេចក្តីសំរេចរបស់ខ្លួន ក្នុងន័យចង់បង្ហាញឱ្យឃើញពីតម្លាភាព និងចង់ឱ្យមានរបៀបច្បាស់លាស់មួយក្នុងការប្រើអំណាចឆន្ទានុសិទ្ធិរបស់អាជ្ញាធររដ្ឋបាលនោះផង ។

. *សំណូមពរ*

មានលិខិតឯកតោភាគី ដែលមិនមែនជាសេចក្តីសំរេចរដ្ឋបាល ហើយដែលគ្រាន់តែជាសំណូមពរដូចជា សំណូមពររបស់ក្រុមប្រឹក្សាឃុំ សង្កាត់ជាដើម ដែលសំណូមពរនេះក៏ជាវិធានផ្ទៃក្នុងរបស់រដ្ឋបាលដែរ មានន័យថាពុំ មានអានុភាពគតិយុត្តអ្វីឡើយ ។

អនុសាសន៍ក៏ជាសំណូមពរមួយបែបទៀត ដែលអាជ្ញាធរថ្នាក់លើអាចលើកឡើងរបៀបស្រដៀងទៅនឹងសេចក្តីបង្គាប់របស់ក្រសួង ប៉ុន្តែមានន័យស្រាលជាងបន្តិច ។ អនុសាសន៍រដ្ឋបាល សំរាប់តែកិច្ចការរដ្ឋបាលផ្ទៃក្នុង មិនមានផលគតិយុត្តប៉ះពាល់ដល់សាធារណៈជនទេ ។ យើងពុំទាន់មានឧទាហរណ៍អំពីសំណូមពរ ឬអនុសាសន៍ រដ្ឋបាលនៅក្នុងនីតិរដ្ឋបាលខ្មែរនៅឡើយ ។ គេប្រទះឃើញនៅក្នុងនីតិរដ្ឋបាលបារាំងមានប្រើនៅក្នុងទំនាក់ទំនងជាមួយអាជ្ញាធររដ្ឋបាលវិមជ្ឈការ ។

. ការងារផ្សេងៗពាក់ព័ន្ធនឹងការរៀបចំសេចក្តីសំរេចរដ្ឋបាល

- ការផ្តល់យោបល់

កិច្ចការរដ្ឋបាល មានច្រើនដំណាក់កាល ទម្រាំបានចេញជាសេចក្តីសំរេច ។ ការផ្តល់យោបល់ផ្សេងៗ របស់ភ្នាក់ងារសាធារណៈដែលពាក់ព័ន្ធជាមុន គឺស្ថិតនៅក្នុងការរៀបចំសេចក្តីសំរេចរដ្ឋបាល ។ គេហៅថា លិខិតរដ្ឋបាល ឯកតោភាគីដែលចូលរួមក្នុងការរៀបចំសេចក្តីសំរេចរដ្ឋបាលមួយ ។

- លិខិតរដ្ឋបាលគំរូ

ដោយរដ្ឋបាលថ្នាក់លើ ចង់ឱ្យមានរបៀបមួយដូចគ្នាក្នុងការចេញសេចក្តីសំរេចរបស់រដ្ឋបាលថ្នាក់ក្រោម ឬ របស់អាជ្ញាធរវិមជ្ឈការ ក្នុងវិស័យអ្វីមួយនោះ ។ អាជ្ញាធរថ្នាក់លើ ធ្វើអត្ថបទ (គំរោង) ជាគំរូដើម្បីផ្តល់ លក្ខណៈងាយស្រួលក្នុងការអនុវត្តន៍ ដោយយោងគ្រប់លិខិតបទដ្ឋានដែលពាក់ព័ន្ធចាំបាច់ ។ អាជ្ញាធរថ្នាក់ក្រោម គ្រាន់តែបំពេញឈ្មោះ និងអាស័យដ្ឋានទៅជាការស្រេច ប្រសិនបើសាមីជនអ្នកសុំ បានបំពេញលក្ខខណ្ឌដូច មានចែងនៅក្នុងគំរូនោះសព្វគ្រប់ហើយ ។

- សេចក្តីជូនដំណឹង

អាជ្ញាធររដ្ឋបាល ត្រូវតែជូនដំណឹងអំពីសេចក្តីសំរេចរបស់ខ្លួន ទៅដល់សាមីជន ។

"សេចក្តីជូនដំណឹង" មិនមែនជាសេចក្តីសំរេចថ្មីមួយផ្សេងទៀតនោះទេ គឺគ្រាន់តែជាលិខិតបែរហាម សេចក្តីសំរេចប៉ុណ្ណោះ ។ សេចក្តីជូនដំណឹង មិនមានអានុភាពគតិយុត្តអ្វីទេ ពីព្រោះពុំមានបន្ថែមវិធានគតិយុត្ត ទៅលើសេចក្តីសំរេច ឬបទបញ្ជាណាមួយឡើយ ។ ការដាក់វិធានបទបញ្ជាទៅក្នុងសេចក្តីជូនដំណឹងណាមួយ ជាការខុសច្បាប់ ដោយមូលហេតុខុសទម្រង់ ។

មេរៀនទី៤ : ការកែប្រែ ការដក និង និរាករណ៍នៃសេចក្តីសំរេចរដ្ឋបាល

ជាការពិតណាស់ លិខិតរដ្ឋបាល ដែលចេញមកហើយ គឺមានគោលដៅដើម្បីយកទៅអនុវត្ត ។ ដូច្នេះ សំនួរដែលចោទមានឡើងគឺ ថាតើនៅពេលណា ដែលលិខិតនេះ*ចូលជាធរមាន*. នៅពេលណា *វាបញ្ចប់ការអនុវត្តន៍* និងចុងបញ្ចប់ តើរដ្ឋបាលត្រូវចាត់*វិធានការបង្កិតបង្ហាំ* យ៉ាងដូចម្តេចចំពោះអ្នកដែល មិនព្រមអនុវត្តតាមសេចក្តីសំរេចរបស់ខ្លួន ។

១- ការចូលជាធរមាននៃលិខិតរដ្ឋបាល (Being in force of administrative act)

លិខិតរដ្ឋបាល មានតំលៃគតិយុត្តតាំងពីវាត្រូវបានចុះហត្ថលេខាដោយម្ចាស់លិខិត (ដូច្នេះ វាអាចត្រូវបានគេប្តឹងពីបទរំលោភអំណាច ដោយពុំចាំបាច់រង់ចាំរហូតដល់វា ត្រូវបានគេផ្សព្វផ្សាយជា សាធារណៈទេ ហើយ ដែលយើងហៅថា អត្ថិភាពនៃសេចក្តីសំរេច) ។ ប៉ុន្តែលិខិតនេះ អាចអនុវត្តទៅលើប្រជាពលរដ្ឋបានតែនៅពេលណាវាត្រូវបានគេ ផ្សព្វផ្សាយត្រឹមត្រូវប៉ុណ្ណោះ ។ ដូចជាច្បាប់ដែរ គោលការណ៍អប្រតិសកម្ម នៃលិខិតរដ្ឋបាលត្រូវបានគេ ទទួលស្គាល់ ។

ក. ការប្រកាសផ្សាយនៃលិខិតរដ្ឋបាល

ជាគោលការណ៍ ការប្រកាសផ្សាយនៃលិខិតរដ្ឋបាល គឺជាការបញ្ជាក់ពីថ្ងៃចូលជាធរមាននៃលិខិតនេះចំពោះប្រជាពលរដ្ឋ ។ ហើយវាក៏ជាចំនុចចាប់ផ្តើមនៃថេរវេលាកំណត់សំរាប់ធ្វើបណ្តឹងពីបទរំលោភអំណាច ដែលអនុញ្ញាតឱ្យមានការជំទាស់ពីនីត្យានុកូលភាពនៃសេចក្តីសំរេចចំពោះមុខចៅក្រម ។

បែបបទនៃការប្រកាសផ្សាយសេចក្តីសំរេចឯកត្តភូត មានលក្ខណៈខុសគ្នាពីលិខិតផ្សេងៗទៀត ។

- សេចក្តីសំរេចឯកត្តភូត មិនអាចដាក់កាតព្វកិច្ចទៅលើពលរដ្ឋណាម្នាក់ទេ ប្រសិនបើពលរដ្ឋនោះមិនត្រូវបានរដ្ឋបាលជូនដំណឹងដោយផ្ទាល់ពីសេចក្តីសំរេច តាមលិខិតម្យ៉ាងអោយឈ្មោះថា វិញ្ញត្តិ។ បែបទនេះ

អាចត្រូវបានលើកលែង ក្នុងករណី វាជាសេចក្តីសំរេច ដែលពាក់ព័ន្ធនឹងមនុស្សជាច្រើន ឬនៅពេលដែលគេមិនស្គាល់អ្នកទាំង នេះ ។

- ផ្ទុយទៅវិញចំពោះសេចក្តីសំរេចទាំងឡាយណា ដែលផ្តល់ផលប្រយោជន៍ដល់ពលរដ្ឋ សេចក្តីសំរេចនោះ អាចអនុវត្តបានភ្លាមៗបន្ទាប់ពីចុះហត្ថលេខា ដោយពុំចាំបាច់មានការជូនដំណឹងទេ ។

ខ. គោលការណ៍អប្រតិសកម្មនៃលិខិតរដ្ឋបាល

ការអនុវត្តលិខិតរដ្ឋបាលមួយ គឺធ្វើឡើងសំរាប់អនាគត ។ ដូច្នេះសេចក្តីសំរេចជាបទបញ្ជា ឬមិនមែនជាបទបញ្ជារបស់រដ្ឋបាល មិនមានឥទ្ធិពលប្រតិសកម្មទេ ។ គោលការណ៍នេះ ក៏មានករណីលើកលែងផងដែរ ព្រោះនៅពេលខ្លះច្បាប់ អនុញ្ញាតឱ្យមានប្រតិសកម្មចំពោះលិខិតរដ្ឋបាលមួយចំនួន ។ ឧទាហរណ៍ : សេចក្តីសំរេចលុបចោលសេចក្តីសំរេចមួយផ្សេងទៀត ដែលតុលាការតម្រូវឱ្យធ្វើ ឬការដកត្រឡប់មកវិញនៃលិខិតរដ្ឋបាល ដែលចេញរួចហើយ ។

២- ការដកមកវិញ និង ការលុបចោល រឺ និរាករណ៍នៃលិខិតរដ្ឋបាល
(Withdrawal and abrogation of administrative act)

ការដកត្រឡប់មកវិញនៃលិខិតរដ្ឋបាល មានលក្ខណៈប្រតិសកម្ម ។ ចំណែកការធ្វើនិរាករណ៍វិញ មានផលប៉ះពាល់សំរាប់អនាគតប៉ុណ្ណោះ គឺមិនពាក់ព័ន្ធនឹងអ្វី ដែលធ្វើកន្លងមកហើយទេ ។ យើងសង្កេតឃើញថា ដោយសារគោលការណ៍អប្រតិសកម្ម ការធ្វើនិរាករណ៍នៃលិខិតរដ្ឋបាល មានលក្ខណៈងាយ-ស្រួលជាងការដកត្រឡប់មកវិញ ។

ការដកត្រឡប់មកវិញ និងការលុបចោល ឬនិរាករណ៍នៃលិខិតរដ្ឋបាល មានលក្ខណៈស្មុកស្មាញ ដែលទាមទារឱ្យយើងសិក្សាលំអិតពីចំនុចនីមួយៗ ។

ក. ការដក រឺ សេចក្តីសំរេចដក

ដោយសារលក្ខណៈប្រតិសកម្មរបស់ខ្លួន ការដកត្រឡប់មកវិញនៃលិខិតរដ្ឋបាល ត្រូវគោរពវិធានចាំបាច់មួយចំនួនខុសៗគ្នាទៅតាមប្រភេទនៃលិខិតទាំងនេះ ។ ការដកមកវិញ អាចធ្វើឡើងទាំងចំពោះលិខិតដែលមានលក្ខណៈត្រឹមត្រូវតាមច្បាប់ និងលិខិតដែលមិនត្រឹមត្រូវតាមច្បាប់ ។

- ការដកមកវិញនៃលិខិតដែលមានលក្ខណៈត្រឹមត្រូវតាមច្បាប់

លិខិតដែលមានលក្ខណៈត្រឹមត្រូវតាមច្បាប់ អាចជាលិខិតបង្កើតសិទ្ធិ ឬមិនបង្កើតសិទ្ធិ ។ ភាគច្រើនសេចក្តីសំរេច ដែលអំណោយផលចំពោះអ្នកទទួលសេចក្តីសំរេច គឺជាលិខិតដែលបង្កើតសិទ្ធិ។ ផ្ទុយទៅវិញជាទូទៅ សេចក្តីសំរេចដែលមិនអំណោយផលចំពោះអ្នកទទួលលិខិត គឺជាលិខិតដែលមិនបង្កើតសិទ្ធិ ។

. ជាគោលការណ៍ ការដកមកវិញនៃលិខិតដែលមានលក្ខណៈត្រឹមត្រូវតាមច្បាប់ និងបង្កើតសិទ្ធិ មិនអាចធ្វើទៅបានទេ លើកលែងតែមានច្បាប់អនុញ្ញាត ឬទៅតាមសេចក្តីសំរេចរបស់ ចៅក្រម ឬទៅតាមការស្នើសុំរបស់អ្នកទទួលផលប្រយោជន៍ពីលិខិតនេះខ្លួនឯង ។

. ផ្ទុយទៅវិញ ការដកមកវិញនៃលិខិតរដ្ឋបាលដែលមានលក្ខណៈត្រឹមត្រូវតាមច្បាប់តែមិនបង្កើតសិទ្ធិ អាចធ្វើឡើងបានគ្រប់ពេលវេលា ។

- ការដកមកវិញនៃលិខិតដែលមានលក្ខណៈមិនត្រឹមត្រូវតាមច្បាប់

ដូចគ្នានេះដែរ យើងត្រូវបែងចែករវាងលិខិត ដែលមានលក្ខណៈមិនត្រឹមត្រូវតាមច្បាប់ បង្កើតសិទ្ធិ និងមិនបង្កើតសិទ្ធិ ។ ទោះបីជាមានលិខិតខ្លះខុសច្បាប់ក៏ដោយ ក៏វាអាចផ្តល់សិទ្ធិចំពោះអ្នក ទទួលបានដែរ (ព្រោះដោយសារវាមិនត្រូវបានគេប្តឹងឱ្យបានទាន់ពេលវេលា) ។

. ប្រសិនបើលិខិតមួយដែលមានលក្ខណៈមិនត្រឹមត្រូវតាមច្បាប់ និងមិនបង្កើតសិទ្ធិ គេអាចដកវាមកវិញបានគ្រប់ពេលវេលា និង គ្រប់មូលហេតុ ។

. ប្រសិនបើលិខិតមួយដែលមានលក្ខណៈមិនត្រឹមត្រូវតាមច្បាប់ តែបង្កើតសិទ្ធិ ការដកមកវិញនៃលិខិតនេះបានលុះត្រាតែវាបំពេញលក្ខខ័ណ្ឌ ២ យ៉ាងគឺ : មានហេតុផលត្រឹមត្រូវដើម្បី

បញ្ចប់អនីត្យានុកូលភាពនៃលិខិត និងត្រូវធ្វើនៅក្នុងរយៈពេលវែលានៃការធ្វើបណ្តឹង ។ នៅប្រទេសបារាំង រយៈពេលនៃការធ្វើបណ្តឹងនេះ ប្រែប្រួលទៅតាមប្រភេទនៃលិខិត តែជាគោលការណ៍គឺមានរយៈពេល ២ ខែ។ ផុតរយៈពេលនៃការធ្វើបណ្តឹង សេចក្តីសំរេចនឹងក្លាយទៅជាស្ថាពរ ទោះបីជាវាខុសច្បាប់ ក៏ដោយ ហើយវាមិនត្រូវបានគេដកមកវិញទេ ដោយសារមូលហេតុគេចង់ថែរក្សា "ស្ថេរភាពស្ថានភាព គតិយុត្តិ" ។

ខ. ការលុបចោល ឬនិរាករណ៍

ដោយសារការលុបចោល ឬនិរាករណ៍នៃលិខិតរដ្ឋបាល មិនមានឥទ្ធិពលគតិយុត្តិប្រតិសកម្ម ទើបវាប្រព្រឹត្តទៅក្នុងលក្ខណៈងាយស្រួលជាងការដកត្រឡប់មកវិញ ។

ការលុបចោល ឬនិរាករណ៍នៃបទបញ្ជា អាចធ្វើបានគ្រប់ពេលវេលាដោយអាជ្ញាធរមានសមត្ថកិច្ច ។ លើសពីនេះ រដ្ឋបាលត្រូវមានកាតព្វកិច្ចលុបចោលបទបញ្ជាណាដែលខុសច្បាប់ ។

ចំណែកការលុបចោល ឬនិរាករណ៍លិខិតដែលមិនជាបទបញ្ជាវិញ ឬសេចក្តីសំរេចឯកត្តភូត គេត្រូវធ្វើការបែងចែករវាងលិខិតដែលបង្កើតសិទ្ធិ និង លិខិតដែលមិនបង្កើតសិទ្ធិ :

- លិខិតដែលមិនបង្កើតសិទ្ធិ អាចត្រូវបានគេលុបចោលនៅពេលណាក៏បាន។
- លិខិតដែលបង្កើតសិទ្ធិ អាចត្រូវបានគេលុបចោល ឬនិរាករណ៍ ទៅតាមលក្ខខណ្ឌកំណត់របស់ច្បាប់ ឬបទបញ្ជា តាមរយៈលិខិតម្យ៉ាងអោយឈ្មោះថា សេចក្តីសំរេចផ្ទុយ ។ ឧទាហរណ៍ : ការតែងតាំងមន្ត្រីរាជការម្នាក់ អាចត្រូវបានគេលុបចោល ឬនិរាករណ៍ លុះត្រាណាតែវាធ្វើតាមនីតិវិធីត្រឹមត្រូវ នៃការដកហូតដំណែង ការចូលនិវត្តន៍ ឬការបញ្ឈប់ពីការងារ ដូចជាដោយសារមូលហេតុខ្វះជំនាញវិជ្ជាជីវៈជាដើម ។

៣.៣- ការអនុវត្តដោយបង្ខំនៃលិខិតរដ្ឋបាល (Forced execution of administrative act)

ជាគោលការណ៍ លិខិតរដ្ឋបាលមិនត្រូវការឱ្យមានការអនុវត្តដោយបង្ខំទេ ។ តែគោលការណ៍នេះក៏មានករណីលើកលែងមួយចំនួនផងដែរ ។

ក. គោលការណ៍ : អវត្តមាននៃការអនុវត្តដោយបង្ខំ

គោលការណ៍ ដែលមិនឱ្យរដ្ឋបាលអនុវត្តសេចក្តីសំរេចរបស់ខ្លួនដោយបង្ខំ ឬដោយប្រើកំលាំង **បង្ខំ** អាចពន្យល់បានតាមលក្ខណៈពីរយ៉ាងគឺ :

តាមលក្ខណៈច្បាប់ សេចក្តីសំរេចរដ្ឋបាលភាគច្រើន អាចអនុវត្តបានតាមផ្លូវច្បាប់ដោយឯកឯង ដោយពុំចាំបាច់ប្រើមធ្យោបាយបង្ខិតបង្ខំបន្ថែមទៀតទេ ។

តាមលក្ខណៈជាក់ស្តែងវិញ វាអាចជាគ្រោះថ្នាក់សំរាប់សេរីភាពរបស់ប្រជាពលរដ្ឋ ប្រសិនបើគេអនុញ្ញាតឱ្យរដ្ឋបាលប្រើប្រាស់មធ្យោបាយបង្ខិតបង្ខំធ្វើជាគោលការណ៍ ។

ព្រោះតាមគោលការណ៍ នៅពេលណាពលរដ្ឋ មិនព្រមអនុវត្តតាមលិខិតរដ្ឋបាលមួយ ពេល នោះខ្លួនអាចប្រឈមមុខនឹងទណ្ឌកម្មផ្សេងៗ តាមផ្លូវច្បាប់រួចជាស្រេចទៅហើយ ។ ទណ្ឌកម្មទាំងនោះអាចជា*ទណ្ឌកម្មព្រហ្មទណ្ឌ* (ឧទាហរណ៍ ការដាក់ទណ្ឌកម្ម ពិបទលហុចំពោះអ្នកដែលបានបំពានទៅលើបទបញ្ជា ដែលបានធ្វើឡើងត្រឹមត្រូវតាមច្បាប់) ឬអាចជា*ទណ្ឌកម្មរដ្ឋបាល* (ឧទាហរណ៍ ការផាកពិន័យ ការដកត្រឡប់មកវិញ ឬការលុបចោលការអនុញ្ញាត ការបិទគ្រឹះស្ថាន ឬទីកន្លែងណាមួយជាដើម) ។

ខ. ករណីលើកលែង: ការអនុវត្តដោយបង្ខំ

ការអនុវត្តដោយបង្ខំ ត្រូវគោរពទៅតាមលក្ខខណ្ឌច្រើនយ៉ាង ។ ការរំលោភបំពានទៅលើលក្ខខ័ណ្ឌទាំងនេះ អាចនឹងត្រូវផ្តន្ទាទោសដោយតុលាការរដ្ឋបាល ឬ ដោយតុលាការស៊ីវិលប្រសិនបើវាជាការរំលោភបំពានទៅលើរូបរាងកាយ ឬសិទ្ធិរបស់ប្រជាពលរដ្ឋ (ករណីប្រមេសបារាំង) ។

- <u>លក្ខខណ្ឌដើម្បីអោយមានភាពស្របច្បាប់នៃការអនុវត្តដោយបង្ខំ</u>

រដ្ឋបាលអាចប្រើប្រាស់របៀបអនុវត្តដោយបង្ខំបានក្នុងករណីបីយ៉ាងគឺ :

. នៅពេលណាមានច្បាប់អនុញ្ញាតឱ្យធ្វើដូច្នេះ ។ ឧទាហរណ៍ : ច្បាប់អនុញ្ញាតឱ្យធ្វើកំណែនកងទ័ពនៅពេលមានសង្គ្រាម... ។

. នៅពេលមានអាសន្ន ឬស្ថានភាពពិសេសខុសពីធម្មតា ។

. នៅពេលគ្មានវិធានការគតិយុត្តណាមួយ ដែលអាចធានាការគោរពសេចក្តីសំរេច (ឧទាហរណ៍ : នៅពេលមិនមានការចែងពីទណ្ឌកម្មព្រហ្មទណ្ឌ ឬទណ្ឌកម្មរដ្ឋបាល)។ ប៉ុន្តែ ក្នុងករណីនេះ ដើម្បីជៀសវាងការរំលោភបំពាន រដ្ឋបាលចាំបាច់ ត្រូវគោរពលក្ខខ័ណ្ឌបីបន្ថែមទៀតគឺ: មានការបដិសេធពិតប្រាកដក្នុងការមិនគោរព ឬអនុវត្តតាមសេចក្តីសំរេច . ប្រតិបត្តិការនៃការអនុវត្តដោយបង្ខំ ត្រូវមានមូលដ្ឋានរបស់ខ្លួននៅក្នុងអត្ថបទច្បាប់មួយច្បាស់លាស់ . វិធានការនៃការអនុវត្តដោយបង្ខំ គឺធ្វើឡើងចាំបាច់សំរាប់តែឱ្យមានការគោរពច្បាប់ប៉ុណ្ណោះ ។

- <u>ទណ្ឌកម្មចំពោះការអនុវត្តដោយបង្ខំដែលមានលក្ខណៈខុសច្បាប់</u>

ការអនុវត្តដោយបង្ខំ អាចមានលក្ខណៈខុសច្បាប់ដោយសារមូលហេតុជាច្រើន និងត្រូវទទួលរងទណ្ឌកម្មផ្សេងៗពីគ្នា :

. ប្រសិនបើរដ្ឋបាល អនុវត្តដោយបង្ខំ*ទៅតាមលក្ខខ័ណ្ឌស្របច្បាប់* ដូចបានរៀបរាប់ខាងលើនូវសេចក្តីសំរេចមួយ ដែល*ខុសច្បាប់* (ឧទាហរណ៍ សេចក្តីសំរេច ដែលត្រូវបានលុបចោលដោយតុលាការ) នោះរដ្ឋបាល ត្រូវសងសោហ៊ុយជំងឺចិត្តចំពោះអ្នកទទួលរងការខូចខាត ។

. ដូចគ្នានេះដែរ រដ្ឋបាលក៏ត្រូវសងសោហ៊ុយជំងឺចិត្តចំពោះអ្នកទទួលរងការខូចខាត ប្រសិនបើខ្លួនអនុវត្តដោយបង្ខំនូវសេចក្តីសំរេចមួយ (ទោះជាស្រប ឬខុសច្បាប់ក្តី) តែ*មិនបានគោរព*ទៅតាមលក្ខខ័ណ្ឌដើម្បីភាពស្របច្បាប់នៃការអនុវត្តដោយបង្ខំទេ ។

. ចុងបញ្ចប់គឺ រដ្ឋបាលប្រព្រឹត្តអំពើរំលោភបំពានទៅលើទ្រព្យសម្បត្តិឯកជន ឬសេរីភាពរបស់ប្រជាពលរដ្ឋ តាមរយៈនូវការបង្កើត*លក្ខខណ្ឌខុសច្បាប់* សំរាប់ការអនុវត្តដោយបង្ខំ ។ ក្នុងករណីនេះ វាជាសមត្ថកិច្ចរបស់តុលាការធម្មតា (ខុសពីករណីពីរខាងលើ ដែលជាសមត្ថកិច្ចរបស់តុលាការរដ្ឋបាល) ក្នុងការបញ្ឈប់សកម្មភាពរំលោភទាំងនេះ និងកំណត់ឱ្យមាន ការសងការខូចខាតដែលកើតមានឡើង ។